**BBI0003**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ឈ្មោះ ម៉ោល សុះ ភេទប្រុស K09204 (បាត់ខ្លួន)
## មុខងារៈ ប្រជាជនសហករណ៍តំបន់៤
## ជួបសម្ភាសន៍ជាមួយលោកតា ហ៊ិន ផាន់ អាយុ ៧៦ ឆ្នាំ ជាអ្នកភូមិ
## នៅភូមិគរ ឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង
## នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៦

ដោយៈ ឆាយ ណារឿន

រឿនៈ ជំរាបសួរតាសូមប្រាប់តាថាពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាអ្នកតាស់ សរសេរទស្សនាវដ្ដីស្វែងរកការពិតនេះ ។ ហើយខ្ញុំមកនេះដោយសារខ្ញុំមានប្រវត្តិរូបមួយឈ្មោះ ម៉ោល សុះ ហើយតាថាស្គាល់គាត់អ្នកតាស់ធ្លាប់រស់នៅជាមួយគ្នាអញ្ចឹងអ្នកតាស់ ហើយខ្ញុំចង់សួរតាខ្លះៗទាក់ទងនឹងប្រវត្តិរបស់គាត់ក៏ដូចជាប្រវត្តិរបស់តាផងដែរដើម្បីយកទៅប្រើ ប្រាស់ជាឯកសារទៅថ្ងៃក្រោយអ្នកតាស់ ។ តាលឈ្មោះអីដែរ?

ផាន់ៈ ខ្ញុំ ហ៊ិន ផាន់ ។

រឿនៈ សព្វថ្ងៃកោលតាអាយុប៉ុន្មានហើយ?

ផាន់ៈ ខ្ញុំ ៧៦ ។

រឿនៈ លោកតាមានជាប់សាច់ញាតិជាមួយ តាសុះ ដែរអត់?

ផាន់ៈ ជាប់ឆ្ងាយដែរហើយ អត់មានជីដូនជីទួតទេវាជាប់ឆ្ងាយទៅ គ្រាន់តែស្គាល់គ្នា ។

រឿនៈ អ្នកភូមិនៅជាមួយគ្នា?

ផាន់ៈ បាទ! នៅជិតគ្នា ។

រឿនៈ លោកតាភូមនេះគេហៅភូមិអីដែរ?

ផាន់ៈ ភូមិខ្ញុំនៅនេះអ្ហែស?

រឿនៈ បាទ!

ផាន់ៈ អាហ្នឹងគេហៅភូមិគរ ។

រឿនៈ ឃុំអីដែរលោកតា?

ផាន់ៈ បើនិយាយពីដើមឃុំជ្រៃ ឥឡូវឃុំព្រៃស្វាយ ។

រឿនៈ នៅស្រុកអីដែរតា?

ផាន់ៈ ស្រុកមោងហ្នឹង ។

រឿនៈ លោកតាមានស្រុកកំណើតកើតជានៅហ្នឹងអ្ហែស?

ផាន់ៈ នៅហ្នឹងកំណើត ដូចម៉ោល សុះ ដែរឃុំជ្រៃ ។

រឿនៈ លោកតា លោកយាយដែលជាគ្រួសារលោកតាឈ្មោះអីដែរ?

ផាន់ៈ ឈ្មោះ មួង ភុំ ។

រឿនៈ គាត់អយុប៉ុន្មានហើយសព្វថ្ងៃ?

ផាន់ៈ ៧៤ ។

រឿនៈ លោកតាមានកូនប៉ុន្មាននាក់ដែរ?

ផាន់ៈ មានបួន ប្រុសពីរ ស្រីពីរ ។

រឿនៈ សព្វថ្ងៃលោកតាប្រកបមុខរបរអីដែរ?

ផាន់ៈ ខ្ញុំមុខរបរធ្វើស្រែ ។

រឿនៈ អញ្ចឹងខ្ញុំសូមសួរតាជំបូងពីប្រវត្តរបស់តាសុះអ្ហាស៎ ។ តាដឹងថា តាសុះ ហ្នឹងឪពុកគាត់ឈ្មោះអីដែរអត់?

ផាន់ៈ ហ្នឹងហើយ ម៉ោល ។

រឿនៈ ឪពុកគាត់ឈ្មោះ ម៉ោល សព្វថ្ងៃគាត់នៅរស់ឬខូចហើយ?

ផាន់ៈ អស់ហើយ ។

រឿនៈ គាត់ស្លាប់សម័យខ្មែរក្រហម ឬក៏មុនទៀត?

ផាន់ៈ ឪពុកគាត់ហ្នឹងមុនទៀត ។

រឿនៈ ចុះម្ដាយរបស់គាត់តា?

ផាន់ៈ ម្ដាយហ្នឹងក៏មុនដែរ ។

រឿនៈ ឈ្មោះអីដែរតា?

ផាន់ៈ ឈ្មោះ សាប ។

រឿនៈ តាដឹងថាតាសុះហឹងគាត់មានបងប្អូនប៉ុន្មាននាក់ដែរអត់?

ផាន់ៈ រាប់មើលសិនមាន បងស៊ុម មីចឹង តាសួត សឿម សុះ ហ្នឹងបណ្ដោយប្រាំនាក់ ។

រឿនៈ ប្រាំទាំងគាត់ ។ ប្រុសប៉ុន្មានស្រីប៉ុន្មានដែរតា?

ផាន់ៈ ប្រុសបី ស្រីតែមួយទេ ។ អ! ប្រុសបួន ។

រឿនៈ ចុះសព្វថ្ងៃនៅសល់ប៉ុន្មានថ្ងៃដែរនៅរស់?

ផាន់ៈ សព្វថ្ងៃដូចមិនសល់ផងអ្ហី ដូចអស់ហើយ សឿម អីងាប់ហើយ អាប្អូនពៅងាប់ហើយ ។ អស់ហើយមិនមាននៅទេ ។

រឿនៈ ស្លាប់សម័យខ្មែរក្រហមឬក្រោយមកទេ?

ផាន់ៈ អ្នកណា?

រឿនៈ បងប្អូនរបស់តាសុះហ្នឹង ។

ផាន់ៈ បងប្អូនរបស់តាសុះហ្នឹងស្លាប់ជំនាន់ខ្មែរក្រហម ។

រឿនៈ ស្លាប់ជំនាន់ខ្មែរក្រហមទាំងអស់?

ផាន់ៈ បាទ!

រឿនៈ តាដឹងថាតាសុះ ហ្នឹងគាត់កើតឆ្នាំអីដែរអត់?

ផាន់ៈ សុះ ហ្នឹងកើតឆ្នាំរាក ។

រឿនៈ បើសិនជានៅរស់សព្វថ្ងៃគាត់អាយុប៉ុន្មាន?

ផាន់ៈ ប្អូនខ្ញុំមួយឆ្នាំគាត់ ៧៥ ។

រឿនៈ ឆ្នាំរាកគាត់អាយុ៧៥ គាត់កើតនៅភូមិឃុំណាដែរ?

ផាន់ៈ ដូចមុនអញ្ចឹង ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

រឿនៈ ភូមិ?

ផាន់ៈ ភូមិតាម៉ុក ។

រឿនៈ ម៉េចគេដាក់ឈ្មោះភូមិហ្នឹងភូមិតាម៉ុកអញ្ចឹង ។

ផាន់ៈ អត់ទេអញ្ចេះចំមើលប្រវត្តិហ្នឹងតាមខ្ញុំសួរពុកខ្ញុំអ្នាស់ ។ ពីដើមសុទ្ធតែព្រៃអស់ហ្នឹងណា ហើយគាត់ទៅឃ្វាលក្របីឃ្វាលគោគាត់ទៅ ធ្វើតំរុយដាក់ខ្ពស់

តំរុយហ្នឹងតាម៉ុកគាត់ប្រុង

ចាប់ដីធ្វើស្រែធ្វើអីក្របីគោអីបាត់អីគេថាក្របីឯងនៅតំរុយតាម៉ុកវើយ

ទៅមើលទៅ តំរុយគាត់ដោតខ្ពស់ណាស់ ។ ដល់អញ្ចឹងតាម៉ុក ៗហ្នឹងជាប់អញ្ចឹងមក ។

រឿនៈ តាម៉ុកហ្នឹងគាត់អ្នកស្រុកណាដែរ?

ផាន់ៈ តាម៉ុកហ្នឹងគាត់អ្នកស្រុកនៅហ្នឹងដែរគាត់ដាក់ធ្វើតំរុយរបស់គាត់

អានេះពុកខ្ញុំគាត់ប្រាប់ ទេណា ខ្ញុំមិនដែលឃើញទេតាម៉ុកហ្នឹងឮតែឈ្មោះ ។

រឿនៈ មិនមែនតាម៉ុកខ្មែរក្រហមហ្នឹងទេអ្ហែស?

ផាន់ៈ អត់ទេ ឈ្មោះដូច ។

រឿនៈ អញ្ចឹងកាលពីមុនហ្នឹងមានចាស់ម្នាក់ឈ្មោះតាម៉ុខហ្នឹង គាត់លើកតំរ៉ុយមួយខ្ពស់នៅភូមិហ្នឹង ។

ផាន់ៈ ពុកខ្ញុំគាត់ថាឯងទៅ ដេរគាត់គេហៅ តែឈោះគាត់ភូមិហ្នឹង ។

រឿនៈ តែមានពីរតាម៉ុក នៅឃុំជ្រៃនេះមួយ តាម៉ុកនៅឃុំរបស់មន្តលណេក ។

ផាន់ៈ អាហ្នឹងតាម៉ុកគេផ្សេង

តាម៉ុកមួយបងប្អូនខ្ញុំដែរពីដើមគាត់ស្លាប់នៅ មោងនេះនៅខាងលើ ផ្សារលើនេះ ។

រឿនៈ អញ្ចឹងខ្ញុំសួរតាបន្តិចទៀត តាសុះ ហ្នឹងកាលគាត់នៅក្មេងគាត់មានបានរៀនបានបួសអីដែរអត់?

ផាន់ៈ បួសបានបួសជាមួយខ្ញុំហ្នឹង ។

រឿនៈ បានបួសបានប៉ុន្មានដែរតា?

ផាន់៖ បួសបានមួយវស្សា ។

រឿន៖ គាត់បួសនៅវត្តណាដែរ?

ផាន់៖ បួសនៅវត្តនេះ ជំនាន់ហ្នឹងគេដាក់ថាវត្តគ្របហិប បានសព្វថ្ងៃគេដាក់សុវណ្ណសាគរ ។

រឿន៖ វត្តគ្រាប់អីគេតា?

ផាន់៖ គ្របហិប ។

រឿន៖ សព្វថ្ងៃគេដាក់ថាវត្តអីវិញ?

ផាន់៖ បច្ចុប្បន្ននេះគេដាក់ថាវត្តសុវណ្ណសាគរ ។

រឿន៖ ហេតុអីបានជាគាត់សឹកពីបួស?

ផាន់៖ មកពីឈឺ ។

រឿន៖ ពេលគាត់សឹកហ្នឹងសម័យសម្តេចស៊ី ហនុ អ្ហែស?

ផាន់៖ មុនសម័យតាស៊ី ហនុ ។

រឿន៖ មុនហ្នឹងទៀត? នៅក្នុងសម័យហ្នឹងជំនាន់សម្តេចឪហ្នឹងអ្ហែស?

ផាន់៖ ហ្នឹងហើយ ។

រឿន៖ អត់ទាន់មានរដ្ឋប្រហា លន់ នល់ ទេ?

ផាន់៖ នៅ រដ្ឋប្រហា លន នល់ ខ្ញុំនេះសឹកមានកូនអីបាត់ទៅហើយ ។

រឿន៖ ពេលហ្នឹងនៅក្នុងសម័យសង្គមរាស្ត្រនិយម ។
ពេលគាត់សឹកហ្នឹងអាយុប្រហែលជាប៉ុន្មាន តា?

ផាន់៖ ពេលសឹកហ្នឹងអាយុប្រហែលជា ២៣ ។

រឿន៖ ពេលគាត់សឹកមកគាត់ធ្វើអីដែរ?

ផាន់៖ អត់មានធ្វើអីទេ ធ្វើតែស្រែហ្នឹង វាកំរិតវប្បធម៌ខ្សោយ ។

រឿន៖ ចុះពេលណាគាត់រៀបការ?

ផាន់៖ រៀបការខ្ញុំភ្លេចហើយ ។

រឿន៖ គាត់សឹកមកបានប៉ុន្មានឆ្នាំ?

ផាន់៖ កន្លងមកប្រហែលជាពីរបីខ្ញុំ ។

រឿន៖ ប្រពន្ធគាត់ឈ្មោះអីដែរ?

ផាន់៖ ប្រពន្ធឈ្មោះ អៀក យឿម ។

រឿន៖ ប្រពន្ធគាត់អ្នកស្រុកណាដែរ?

ផាន់៖ នៅជាមួយគ្នាហ្នឹង ។

រឿន៖ អ្នកភូមិតាម៉ុកដែរ?

ផាន់៖ បាទ! នៅផ្ទះជិតគ្នាហ្នឹង ។

រឿន៖ គាត់រៀបការនៅសម័យសម្តេច ស៊ី ហនុ ដែរ?

ផាន់៖ ហ្នឹងហើយ សង្គមរាស្ត្រនិយមយម ។

រឿន៖ ពេលគាត់រៀបការហ្នឹងតាសឹកហើយនៅ?

ផាន់៖ ខ្ញុំសឹកហើយដែរ ខ្ញុំបានតែពីរវស្សា បួសនេនជងបានបួនវស្សា ។

រឿន៖ ពេលគាត់រៀបការហើយអញ្ចឹងគាត់ធ្វើអីដែរ?

ផាន់៖ ធ្វើស្រែ ។

រឿន៖ អញ្ចឹងរហូតដល់ឆ្នាំមានរដ្ឋប្រហារទម្លាក់សម្តេច ស៊ី ហនុ គាត់នៅស្រុកភូមិដដែលទេ?

ផាន់៖ នៅតែហ្នឹង ។

រឿន៖ ចុះគាត់ធ្វើអីដែរ?

ផាន់៖ អត់មានរបរអីទេ ។

រឿន៖ ចុះដល់ពេលគេទម្លាក់សម្តេចហើយនៅតាមភូមិឃុំនេះមានសភាពយ៉ាងម៉េចដែរតា?

ផាន់៖ អាហ្នឹងគ្រាន់តែគេចខ្លួនទេ គេចខ្លួនពីខ្មែរក្រហមដែរណា គេចទៅក្រោមអីណាដូចថាគេចទៅនៅខាង....អីអញ្ចឹងទៅឲ្យផុតពីគំនាបខ្មែរក្រហម ។

រឿន៖ អញ្ចឹងនៅ...

ផាន់៖ អត់បានទៅធ្វើខ្មែរក្រហមអីគេទេ ។

រឿន៖ គាត់អត់មានបានចូលអីទៅអ្វើសកាលហ្នុង តាសុះអ្ហាស់?

ផាន់:	អត់ទេកាលហ្នឹងវាទៅអាដែលយើងពេលជ័យជំនះ៧៥អញ្ចឹងអ្ហែសខ្មែរក្រហម?

រឿនៈ	បាទ! ៧៥ ។

ផាន់:	ទៅទាំងខ្ញុំអីឯងទៅ នៅណាបើកណ្តាប់ដៃគេទៅ ហើយ ។

រឿនៈ	ចុះមុន៧៥?

ផាន់:	មុន ៧៥ គ្នារត់ទៅ នៅ ជ្រៃ មោងអីណាគេចពីខ្មែរក្រហម ។

រឿនៈ	មានខ្មែរក្រហមមកដល់ភូមិអីដែរទេ?

ផាន់:	ជំនាន់ហ្នឹងសុទ្ធតែខ្មែរក្រហមឆ្នាំយើង ៧៥ ហ្នឹងខ្មែរក្រហមវារំដោះបានអ្ហាស់ ៧៦,៧៧ ហ្នឹងអស់នេះរត់ខ្ទេចអស់ហើយចោលភូមិហើយ

អាណាទៅណុះចូលខ្មែរក្រហមក៏ចូលទៅ អាណាទៅចូលខាងតា នល់ ក៏ទៅ ។

រឿនៈ	ពេល លន់ នល់ ធ្វើរដ្ឋប្រហារហើយហ្នឹងអ្ហែស?

ផាន់:	ហ្នឹងហើយ ។

រឿនៈ	ពេលហ្នឹងមិនមានពីរខាង លន់ នល់ មួយខាង ខ្មែរក្រហមមួយ ។

ផាន់:	កន្លែងខ្ញុំនេះគេដាក់ថាតំបន់រុញច្រាន ទាហានមកអាខ្មែរក្រហមចេញទៅ ដល់អាទាហាន ទៅវិញអាខ្មែរក្រហមនៅហ្នឹង អាហ្នឹងគេហៅតំបន់រុញច្រាន ។

រឿនៈ	អញ្ចឹងដូចគ្នាហ្នឹងនៅកន្លែងខ្លះគេហៅតំបន់ប្រទាញប្រទង់ដែរ?

ផាន់:	ហ្នឹងហើយ ។

រឿនៈ	អញ្ចឹងពេលហ្នឹងដូចថាទាហានខ្មែរក្រហមមកអញ្ចឹងទៅ ប្រជាជន....

ផាន់:	អត់ទេគេចអស់ហើយ ដូចថាពួកទាហានគេចុះមកមានគ្នាគេច្រើនអី កប៉ាល់ហោះកាល ហ្នឹងពួក លន់ នល់ កប៉ាល់ហោះគេមកឆ្វែលអី ពួកគេគេចអស់ទៅ ។ ហើយប្រជាជន នៅស្វាយ នៅជ្រៃនៅអីរត់អស់ហើយកន្លែងនេះវាទៅជាកន្លែងសមរភូមិហើយតើ ។

រឿនៈ	ពេលហ្នឹងតាសុះអីតាអីរត់ទៅណាដែរអត់នៅក្នុងតំបន់រុញច្រានអញ្ចឹង?

ផាន់:	ខ្ញុំរត់ទៅនៅមោង ។

រឿនៈ	នៅទីរួមស្រុកតែម្តងអ្ហែស នៅផ្សារមោងហ្នឹង?

ផាន់: បាទ! នៅផ្សារមោងហ្នឹង ។

រឿន: ចុះតាសុះ?

ផាន់: តាសុះ គាត់ទៅខាងជ្រៃ ។

រឿន: ទៅជ្រៃវិញ ។ ចុះពេលដូចថាសម័យលន់ នល់ រដ្ឋប្រហារហើយនៅតាមស្រុកភូមិនេះមានទម្លាក់គ្រាប់បែកដែរអត់?

ផាន់: កន្លែងនេះអត់មានទេ មានតែទម្លាក់នៅណេក ខាងដូនទ្រី ចាករ ។

រឿន: អញ្ចឹងម្តុំនេះអត់មានទេអញ្ចឹង?

ផាន់: អត់ទេកាលហ្នុងវាគ្រាន់តែមកឆាបមើលទេ ។

រឿន: ហេតុអីបានជាអត់មានទម្លាក់គ្រាប់បែកអញ្ចឹងតា?

ផាន់: អានេះដូចខ្ញុំថាអញ្ចឹងតំបន់រុញច្រានវាអត់មានទីតាំង អាកន្លែងនោះវាមានទីតាំងខ្មែរក្រហម ។

រឿន: អញ្ចឹងអានេះគ្រាន់តែជាសមរភូមិគេរុញទៅរុញមក តែមូលដ្ឋានយោធាអត់នៅនេះទេ?

ផាន់: អត់ទេវាគ្រាន់តែមកមួយភ្លែតៗទេ ។

រឿន: អញ្ចឹងតាដូចថាពេលមានទាហានខ្មែរក្រហមអីចេញចូលស្រុកភូមិអី ពួកហ្នឹងដែលកៀរប្រជាជនទៅជាមួយដែរអត់?

ផាន់: កៀរដែរតើ ។ កៀរយប់ ខទាហរព័ថាប្រជាជនគ្នាទៅ នៅអញ្ចឹងទៅស្រូវស្រែគ្នាមកលួចប្រូតអីអញ្ចឹងណា ហើយវាដឹបូងឡើយវាធ្វើនយោបាយថាមករត់ទៅហ្នុងបានអីស៊ីទៅ ស៊ីថ្មថ្មល់ហ្នឹងបានអីនយោបាយគេណា មកចុះពួកខាងអង្គការយើងអត់មានធ្វើអីទេ មកប្រូតមកអីទៅ ខ្ញុំក៏មកដែរតែមកក្នុងមិនទុកចិត្តណា ។ ខ្ញុំអត់ដេកទេ មកអញ្ចឹងបែនបានមួយបាវពីរបាវអញ្ចឹងដាក់រទេះបរទៅដេកមោងវិញ ។ អត់ទុកចិត្ត តែអាខ្លះគេទុកចិត្តណាដេកហ្នឹងនៅហ្នឹងនៅស្រូវហ្នឹង ។ហើយវាចេះតែធ្វើៗយូរៗទៅមនុស្សចេះតែមកចុះវាអត់ទៅ នៅហ្នុងបានអីស៊ីបើមិនរកស្រូវ ដល់មកបានច្រើនៗមកវាធ្វើផែនការ

សម្ងាត់របស់វា យប់ឡើងវាយកយោធាអីរបស់វា យកមកវាក្រវ៉ាត់ភូមិវិញ ។ ខ្ញុំបានអីវិញខ្ញុំអត់ទុកចិត្ត ។

រឿនៈ មានប្រជាជនច្រើនអត់ដែលខ្មែរក្រហមវិញទៅ?

ផាន់ៈ អាហ្នឹងដល់វារឹបទៅខ្លះក៏រត់រួច បងខ្ញុំនេះបររគេះទៅដល់ផុតឆ្ងាយបន្តិច គាត់វាងទៅមោង ។

រឿនៈ មានដូចថាប្រជាជនយើងមួយចំនួនចង់ចូលដៃរអត់កាលហ្នុង?

ផាន់ៈ ទេ គេចូលច្រើនណា មុំភូមិសុះនៅហ្នឹងទៅពីតាម៉ុកទៅ មានទួលទ្រា ចុងខ្ទះ បឹងរូង ។

រឿនៈ គេស្មគ្រចិត្តចូលអ្អែស?

ផាន់ៈ បាទ! ដល់គេមកវិញគេធ្វើចៅហ្វាយលើឯងគេមូលដ្ឋាន ។

រឿនៈ គេថាគេមូលដ្ឋាន?

ផាន់ៈ ចារ នេះអាភូមិចារ ជិតនេះក៏ទៅដែរ តែវាទៅមិនអស់ណា ហើយភូមិខ្ពស់នេះក៏មានទៅដែរតែទៅតិច ។

រឿនៈ ចុះតាដូចថាដល់ឆ្នាំ៧៥ខ្មែរក្រហមវ៉ៃបែកភ្នំពេញហើយណា លន់ នល់ ដួលរលំ គេមានជម្លាសប្រជាជនថ្មីមកពីភ្នំពេញដែរអត់?

ផាន់ៈ មកកន្លែងនេះអ្អែស?

រឿនៈ បាទ!

ផាន់ៈ មាន តែខ្ញុំសួរទៅខ្លះក៏នៅខេត្តកណ្តាល ខេត្តអីអញ្ចឹងទៅណា កន្លែងនេះក៏នៅដែរ តែខ្ញុំរត់ទៅ នៅពោធិសាត់ណ៎ា ពេលគេវ៉ៃបែកមោងអ្ហាស៎ដល់មកគេឲ្យទៅ នៅភូមិទួលទ្រាខាងកើតតាម៉ុកហ្នឹងណា ។ដល់នៅអញ្ចឹងបានប្រហែលពីរខែធ្វើស្រែធ្វើអីហើយគេថាទៅ នៅនោះកន្លែងម្រះព្រៅអីណាក៏ឡើងទៅហ្នឹងទៅកន្លែងនេះឲ្យពួកមកពីភ្នំពេញនេវ ។

រឿនៈ អញ្ចឹងនៅភូមិគរនេះ អ្នកមកពីភ្នំពេញនៅហ្នឹងទេ?

ផាន់ៈ នៅហ្នឹងនៅដល់តាម៉ុក ទួលទ្រាអីណ៎ា ។

រឿនៈ ចុះសុះ តាសុះទៅណាវិញ?

ផាន់ៈ តាសុះគាត់ឡើងទៅ នៅ ជ្រៃ ។

រឿនៈ តាដឹងដំណឹងតាសុះទៀតប្អត់ពេលហ្នុង?

ផាន់ៈ ដឹងកាលជំនាន់ហ្នុងគេអត់មានឲ្យយើងដើរទាក់ទងមិត្តភក្តិអីទេ គិតតែពីរឿងការងារទេ អត់បានទេដឹងថានៅ តែអត់បានជួបគ្នា ។ ដល់គាត់នៅ ហ្នឹងទៅ គេជម្លាសយកទៅជួយខាងយើងនៅ ចាករ ទួលតាម៉ាកអីគេឲ្យយើងទៅ ធ្វើស្រែហ្នឹង ។

រឿនៈ ចាករគ្រាន?

ផាន់ៈ បាទ! ហ្នឹងហើយ ឲ្យទៅ ធ្វើស្រែហ្នឹងបានគេចាប់គាត់អីហ្នឹងណា ព្វពីហ្នឹងទៅ ប្រជាជនគេជ្រៃទៅ ប្រជាជនស្លាប់ឆ្នាំ៧៦ស្លាប់អស់ច្រើនទៅ ។ខ្ញុំអីគេចង់ជ្រៃទៅដូនទ្រើដែរតើ មិនដឹង យ៉ាំងម៉េចទេ ហេតុតែបុណ្យជួយបានគេឈប់ទៅវិញ ជិតជ្រៃហើយតើ គេចុះឈ្មោះ ចុះអីហើយជំនាន់ហ្នុងអាណាហានប្រកែក ។

រឿនៈ តាខ្ញុំសួរបកក្រោយបន្តិចដូចថាកាល លន់ នល់ ធ្វើរដ្ឋប្រហារហើយហ្នឹង គេមានឃោសនាឲ្យយើងចូលព្រៃអីដែរអត់កាល់ហ្នុង?

ផាន់ៈ មានមិនអត់ទេ គេថាឲ្យយើងចូលព្រៃទៅ ដើម្បីរំដោះប្រទេសជាតិអាហ្នឹងមានតែឃោស នាទៅ អ្នកណាគេទៅក៏ទៅ ៗ អ្នកណាមិនទៅដូចខ្ញុំអីអត់ទៅ ទេទៅ នៅ លើចុងឈើអីទឹកទន្លេលេចអាកន្លែងសមរភូមិគេនៅ ហ្នឹទឹកទន្លេលិចកំពស់ប្រហែលជាប្រាំប្រាំមួយម៉ែតខែវស្សាណ៎ទៅ នៅ ធ្វើលើចុងឈើណ៎ ហើយដែលអន្កបាយអីហ្នឹងទូកគេទៅទាក់ ទងយកមក លើកចង្ក្រានដាំលើចុងឈើហ្នឹងមិនធម្មតាទេ អញ្ចឹងបានថាគេតស៊ូរខ្លាំងណាស់ណាគេមកវិញគេមានជ័យជំនះឯងមិនហ៊ានមើលមុខគេទេ គេមកវិញបន្ទាប់ ឯង ។

រឿនៈ ពីណាគេអ្នកចលនានៅ តាមភូមិតាមស្រុកយើង?

ផាន់ៈ អាពួកខ្មែរក្រហមហ្នឹង នៅ ម្តុំភូមិបឹងវេង ខាងកើតនេះ ឈ្មោះ ចន ។

រឿនៈ ឈ្មោះ ចន អ្វែស?

ផាន់៖ បាទ! តែឥឡូវផាប់បាត់ហើយ ។

រឿន៖ ចន ហ្នឹងគាត់អ្នកឃោសនាតាមហ្នឹង?

ផាន់៖ ហ្នឹងហើយ ដល់គាត់បានជយ័ជុំនះគាត់ធ្វើគណៈសហករណ៍ ។

រឿន៖ ចន ហ្នឹងគាត់អ្នកឃោសនាតាមភូមិ?

ផាន់៖ បាទ!

រឿន៖ អ្នកភូមិណាតា ចន ហ្នឹង?

ផាន់៖ អ្នកភូមិបឹងរូងហ្នឹង ។

រឿន៖ គាត់ឃោសនាថាម៉េចតា?

ផាន់៖ ឃោសនាដើម្បីបញ្ចុះបញ្ចូលឲ្យយើងចូលព្រៃអ្នកឆ្លាស់ មកធ្វើអីនៅជាមួយខ្មាំង ។

រឿន៖ ចុះពេលបានជ័យជំនះហើយតាចនហ្នឹងគាតឡើងធ្វើអីដែរ?

ផាន់៖ ឡើងធ្វើគណៈសហករណ៍ ។

រឿន៖ នៅណាដែរ?

ផាន់៖ នៅភូមិម្រះព្រៅ ។

រឿន៖ នៅត្រង់ណាភូមិម្រះព្រៅហ្នឹង?

ផាន់៖ នៅនេះចុះពីហ្នឹងទៅប្រហែលជាបួនគីឡូ ។

រឿន៖ តាដូចថាពេលជយ័ជំនះ១៧មេសា ខ្មែរក្រហមវ៉ៃបែកភ្នំពេញហើយ ចុះនៅបាត់ដំបង
នៅស្រុកមោងនេះវ៉ៃបែកឆ្នាំណាដែរ?

ផាន់៖ មោងវ៉ៃបែក ៧៣, ៧៤ ខ្ញុំរត់ទៅនោះ ចូល៧៥ ខ្មែក្រហមទទួលជ័យជំនះហើយណា
ចូលឆ្នាំហ្នឹងខែពិសាខ ។

រឿន៖ ដូចថាខ្មែរក្រហមវ៉ៃបែកមោងហ៊ឹងមុនវ៉ៃបែកភ្នំពេញ ឬក្រោយវ៉ៃបែកភ្នំពេញ?

ផាន់៖ មុន មោងបែកមុន ។

រឿន៖ មុនប៉ុន្មានថ្ងៃ?

ផាន់៖ ទេអត់បានរាប់ទេ ។

រឿនៈ បែកចំថ្ងៃចូលឆ្នាំដែរអត់?

ផាន់: មុនប្រហែលជាកន្លះខែ ខ្ញុំរត់ទៅនៅពោធិសាត់ រឺបែកមោងយើងពី៧៤ខ្ញុំរត់ទៅនៅពោធិសាត់ហើយណា ដូចជាដើមឆ្នាំ ៧៤ហ្នឹង ។

រឿនៈ ដើម ៧៤?

ផាន់: ដើមឆ្នាំ៧៤ ខ្ញុំទៅនៅពោធិសាត់អត់បានមួយឆ្នាំទេប្រហែលជា៣ខែទេ ។

រឿនៈ បានបែកមោង?

ផាន់: អត់ទេ បែកមោងហ្នឹងរត់បណ្តោយរត់ទៅនៅពោធិសាត់ ។

រឿនៈ ប៉ុន្មានខែបានបែកភ្នំពេញ?

ផាន់: បីខែចុះ អានេះមិនបានកត់ត្រាណា៎ បានជ័យជំនះហ្នឹងបណ្តោយ ។

រឿនៈ អញ្ចឹងដើមឆ្នាំ ៧៥ ហើយព្រោះថាជ័យជំនះខ្មែរក្រហមថ្ងៃ១៧មេសា ខែ៤អ្ហាស៎ ។

ផាន់: ហ្នឹងហើយដើម៧៥ តែអានេះបើហើងចូលឆ្នាំយើងគិតតាមពុទ្ធសករាជទេណា តែគ្រឹសរាជវាចូលតាំងពីខែមាឃខែមួយម្ល៉េះ ។

រឿនៈ បាទ! ខែមួយ ។

ផាន់: អញ្ចឹងហើយរត់ទៅហ្នឹងខ្ញុំមានស្រូវដឹកបាវអីរត់ទៅ ដូចខែមាឃ ផល្គុនអីហ្នឹង ។

រឿនៈ ចុះពេលរឺបែកមោងតាដឹងដំណឹងតាសុះទៀតដែរអត់?

ផាន់: អាហ្នឹងបែកគ្នាហើយរត់យកអាយុរៀងខ្លួនហើយមិនដឹងទៅណាណីទេ
ហើយគេមិនដឹងទៅ តំបន់ខ្មែរក្រហមដែរមិនដឹង ហើយក៏មិនដឹងទៅខាងណាទេ ។
គាត់ហ្នឹងបើនិយាយពីប្រវត្តិ
គាត់ទៅគាត់អត់មានទៅធ្វើប្រទូសអីជាមួយខ្មែរក្រហមទេ បើគេនៅតែទៅក៏គេមិនសម្លាប់ដែរ ដូចខ្ញុំបើខ្ញុំទៅខ្មែរក្រហមក៏គ្មាននរណាសម្លាប់ខ្ញុំដែរ ខ្ញុំមិនដែលទៅប្រទូសអីជាមួយខ្មែរក្រហមផង ។ ទៅជួបនៅមុខហ្នឹង ។

រឿនៈ ជួបគាត់ពេលណាដែរតា?

ផាន់: ជួបខ្មែរក្រហមហ្នឹង?

រឿនៈ អត់ទេជួបតាសុះ ។

ផាន់ៈ តាំងពីបែកមោងមកអត់ដែលជួបទេ ដូចខ្ញុំដែលរត់ទៅមោងហ្នឹង ធ្វើស្រែអីហ្នឹងជួបមេខ្មែរក្រហមដូចខ្ញុំប្រាប់ថាចនអីមុិញហ្នឹង

តែអត់មានធ្វើអីខ្ញុំផងគាត់ថាល្បងឯងល្មមត្រឡប់ មកនៅនេះវិញហើយអ្ហី ទៅនៅជាមួយខ្មាំង ។ ត្បិតអីគាត់ហ្នឹងពីដើមគាត់ចោរអ្ហាស៎ ចោរលួចក្របីអីហ្នឹង ដល់អញ្ចឹងខ្ញុំជាមួយមាខ្ញុំហ្នឹងធ្វើមេកងនេះជំនាន់តាសុី ហនុ អ្ហាស៎ ជំនាន់យុវាន់អ្ហាស៎ ដល់អញ្ចឹងគាត់ហ្នឹងលួចក្របីគេមកចងបីងរួងហ្នឹងគេដឹងមេឃុំគេឲ្យ

សំបុត្រមកថាឲ្យទៅចាប់យកក្របីពីឈ្មោះ ចន ហ្នឹង

ដល់ទៅហ្នឹងបងខ្ញុំដីដូនមួយហ្នឹងគាត់

រកចងរកវៃអីអីអញ្ចឹងខ្ញុំថាកុំធ្វើគាត់អត់អីទេមនុស្សនេះ ខ្ញុំធ្វើនយោបាយអ្ហាស៎ ។ បងខ្ញុំគាត់អត់សួរដឹងអីទេឈ្មោះតាអឿកហ្នឹង ។ កុំចងកុំធ្វើគាត់ ឥឡូវក្របីទុកនៅហ្នឹងហើយ ឥឡូវអញ្ចេះចុះ ឥឡូវចនឯងបើចងមានអាណាដឹកក្របី ឯងវាជាប់កាន់កាំភ្លើងកាន់អីដែរ ។ ចោរបើមិនកាន់កាំភ្លើងវាមិនខ្លាចយើងទេណា សំឡុតឯងវិញឥឡូវហ្នឹង ដល់អញ្ចឹងឲ្យដឹកក្របីមក ដើរមកខ្ញុំប្រាប់ថា ចន ឯងអត់ជាប់គុកទេ ម៉េចបានអត់ជាប់គុក បានក្របីមួយយកមកឲ្យមេឃុំរួចខ្លួនហើយ មិនបាច់រត់ទេ រត់ស្មានថារួចអ្ហើស កាំភ្លើងខ្ញុំចូលគ្រាប់ហើយ រត់អត់រួចទេរត់ខ្ញុំបាញ់បាក់ជើងឥឡូវហ្នឹង ខ្ញុំសំឡុតអ្ហាស៎ ។ អត់អីទេដឹកមកដល់ភូមិគរនេះឲ្យដេក អីហ្នឹងទៅព្រឹកឡើងបានយកក្របីឲ្យគេណា ។ អត់ទេតាមខ្ញុំអញ្ចឹងគាត់ដឹងថាខ្ញុំមនុស្សស្លូតបូតណា៎ ដឹងថាខ្ញុំស្លូតបូបអញ្ចឹង ខ្ញុំឃាត់ឃាំង មិនឲ្យចងអីទាំងអស់

ព្រឹកឡើងយកក្របីអីទៅឲ្យគេដូចខ្ញុំថាអញ្ចឹងគេឲ្យមកវិញបាត់គេបាន ក្របីវិញហើយរឿងអី ។

រឿនៈ គាត់ដឹងគុណតា ។

ផាន់ៈ បាទ! ដឹងដែរហ្នឹងណា មនុស្សដឹងគុណអញ្ចឹងដែរណាយើងធ្វើល្អ ។

រឿន៖ ចុះតាដឹងថាក្រោយមកទៀតតាសុះ ហ្នឹងយ៉ាងម៉េចបានត្រូវគេចាប់?

ផាន់៖ ដែលខ្មែរក្រហមចាប់ហ្នឹង?

រឿន៖ បាទ!

ផាន់៖ ដូចខ្ញុំនិយាយម៉ិញអញ្ចឹងថាគាត់ហ្នឹងនិយាយពីរឿងកាលវៀតណាមចូលមករំដោះអីហ្នឹង មិនទាន់មកដល់ផងគ្រាន់តែឮថាវៀតណាម គេមិនចូលខាងនោះណាខាងសៀមរាប កំពង់ធំមុនណា ហើយអានោះចូលមកពោធិសាត់មកចាប់ដៃគ្នាស្រុកមោងនេះហើយ ខ្មែរក្រហមវានៅហ្នុងនៅឡើយវាមិនទាន់រត់អីវា វាគ្រាន់តែដឹកស្រូវអីទៅលើ ហើយសុះ ហ្នឹងគេនិយាយខ្សឹបៗអ្នកស្រុកអាហ្នឹងសុទ្ធតែគ្នាឯងអញ្ចឹងថា យើងបន្តិចទៀតបានស្រួល ហើយ ដល់អាហ្នឹងវាទៅនិយាយប្រាប់អាខ្មែរក្រហមចាប់គ្រឹបវ៉ៃចោលហើយ ខ្មែរក្រហមអត់ទុកទេ អត់ទុកសោះអានិយាយអញ្ចឹង ។

រឿន៖ តាម៉េចដឹងថាគាត់និយាយអញ្ចឹងកាលហ្នុងតានៅជាមួយគាត់ដែរអត់?

ផាន់៖ អត់នៅទេ អានេះដំណឹងដឹងគេប្រាប់ថាសុះស្លាប់បាត់ហើយ អានេះដល់យើងវៀតណាម មកជួបគ្នាអ្នកស្រុក អាមកពីណាណីមកជួបជុំគ្នាសួរទៅថា សុះ អាណិតគ្នាណាស់គេវ៉ៃ ចោលហើយ ។ ខ្ញុំថាវ៉ៃរឿងអីវានិយាយដូចខ្ញុំនិយាយប្រាប់ម៉ិញអញ្ចឹងណា ។

រឿន៖ តាជួបពីណាគេប្រាប់តាអញ្ចឹង?

ផាន់៖ អាហ្នឹងខ្ញុំភ្លេចគេបាត់ហើយស្គាល់គ្នាច្រើនណាស់គ្នាឯង ។

រឿន៖ ចុះប្រពន្ធកូនគាត់តា?

ផាន់៖ ប្រពន្ធកូនគាត់នៅជ្រៃនេះ មិនស្រួលស្លាប់បាត់ហើយតើអ្ហី ។

រឿន៖ ចុះកូនគាត់បួននាក់ទៀតនោះ?

ផាន់៖ កូនវាឆ្ងាយពីគ្នាមិនដឹងទៅណាទេ ។

រឿន៖ អញ្ចឹងគាត់ស្លាប់ដោយសាគាត់និយាយមិនបានគិតអ្ហែស?

ផាន់៖ បាទ! អត់បានគិត ។

រឿនៈ	អញ្ចឹងតានៅក្នុងសម័យខ្មែរក្រហមតាដឹងថាគាត់មានឋានៈស្អីដែរតាសុះហ្នឹង?

ផាន់ៈ	តាសុះ ហ្នឹងដូចខ្ញុំប្រាប់ហើយឯង១៧មិនដែលបានធ្វើអីទេ ។ ប្រជាជនថ្មីគេមិនឲ្យធ្វើអីទេ ឲ្យគេមូលដ្ឋានអាមិនចេះអក្សរមួយអន្តក៏គេឲ្យមកត្រួតឯងដែរ ដល់ទុកអញ្ចឹងវាស់ដីមិនដឹងហិចតាប៉ុន្មានហិចតាប៉ុន្មានផង ។ ហើយខ្ញុំនេះគេកើនឲ្យលើកភ្លឺមានតាមួយកាន់សៀវភៅអីដើរវាស់ដីអញ្ចឹងអត់ដឹងណា៎ ហើយសួរខ្ញុំគោះប្អូនៗឯងចេះគិតហិចតាអីដែរ ទេ? ខ្ញុំថាថីក៏មិនចេះ អើអញ្ចឹងមិនបាច់លើកភ្លឺទេដើរតាមខ្ញុំឯងបានស្រួលបន្តិចហើយ វាអត់ដឹងប៉ុន្មានមួយហិចតា.... ។

រឿនៈ	ចុះតាដូចថាពេលខ្មែរក្រហមកាន់វៃបែកភ្នំពេញគេជម្លាសតា គេរុញតាទៅណាដែរ?

ផាន់ៈ	ខ្ញុំដូចខ្ញុំប្រាប់អញ្ចឹងថាជម្លាសពីនេះទៅ នៅម្រះព្រៅ នេះណា៎ ។

រឿនៈ	ចុះ៧៥ ?

ផាន់ៈ	អា៧៥ហ្នឹងទៅពោធិសាត់ មកពីពោធិសាត់ខ្ញុំប្រាប់ក្មួយឯងថាមកនៅទួលទ្រានេះដល់គេជម្លាសពីទួលទ្រាទៅ នៅម្រះព្រៅណា
អាកន្លែងអស់នេះអាដួរក្រោមនេះគេឲ្យអ្នក ខាងភ្នំពេញមកនៅ ។

រឿនៈ	អ្នកខាងភ្នំពេញមកនៅច្រើនដែរអត់តា?

ផាន់ៈ	អរច្រើន តែមិនដឹងកន្លែងណា មិនមែនមាននៅតែកន្លែងនេះមួយដុំទេណា មានបន្តរហូតទៅនោះទៀត ហើយទៅអាខ្លះទៅប៉ែកខាងលើ ។ អ្នកដែលមកមានសាប់គ្រួសារ ម៉ែឪបងប្អូនតិចមកៗ ធ្វើបុណ្យ ។

រឿនៈ	ចុះតាកាលដែលនៅនេះ តាមានត្រឡប់មកនៅភូមិនេះវិញទេ?

ផាន់ៈ	កាលជំនាន់ខ្មែរក្រហមហ្នឹងអ្អែស?

រឿនៈ	បាទ!

ផាន់ៈ	អត់ទេទាល់តែវៀតណាមរំដោះបានមកវិញ ។

រឿនៈ	ដំបូងតានៅពោធិសាត់ ដល់ក្រោយមកនៅម្រះព្រៅ?

ផាន់ៈ	នៅទួលទ្រា ។

រឿនៈ	ទួលទ្រាកាលហ្នុងពីណាគេក្ដាប់នៅទួលទ្រាហ្នឹង?

ផាន់ៈ	ឈ្មោះ ព្រីង ៗ,

រឿនៈ	តាព្រីងហ្នឹងគាត់ក្ដាប់សហករណ៍ឬក្ដាប់អី?

ផាន់ៈ	អត់ទេអានេះក្ដាប់......

**ចប់សាយអេ កាសែ្សតទីមួយ**

ផាន់ៈ	អាណាធ្វើអី ធ្វើដេបេអី ធ្វើទាហានធ្វើអីគេស្រាវជ្រាវណា...ណា៎ កន្លែងគេស្រាវជ្រាវណា៎ ៗ

រឿនៈ	មានគេស្រាវជ្រាវចាប់មនុស្សបានដែរទេ?

ផាន់ៈ	អាហ្នឹងគេធ្វើអញ្ចេះគេមិនមែនធ្វើវុះវះអញ្ចឹងទេ ៗ

រឿនៈ	មុនដំបូងគេធ្វើយ៉ាងម៉េច?

ផាន់ៈ	មុនដំបូងគេហៅទៅ យើងប្រុសៗអ្នាស៎ ស្រីៗគេអត់ទេ គេហៅប្រុសៗទៅគេសួរដូចថា ឥឡូវយើងទៅសម្ដែងការស្មោះត្រង់ចំពោះអង្គការយើង ៗមិនមែនរំដោះមកសម្លាប់ទេ ដើម្បីរំដោះប្រទេសដើម្បីកសាងប្រទេស និយាយអញ្ចឹងណា៎ ដើម្បីកសាងប្រទេស ហើយបើបងណាប្អូនណាធ្វើអីក៏ដោយ ឌីបេ ក៏ដោយស្ពីក៏ដោយសម្ដែងឲ្យស្មោះត្រង់ចំពោះអង្គការយើង ៗលើកលែងទោសឲ្យ ហើយខ្ញុំវាមានអាបញ្ហាមួយក្នុងពោះមិនហ៊ាននិយាយប្រាប់គេអី ក្រែងវាយកអាពាក្យហ្នឹងទៅនិយាយប្រាប់គេផាប់ ៗ

រឿនៈ	តានៅស្ងៀម ៗ

ផាន់ៈ	បាទ! ទុកតែក្នុងខ្លួនទេ ដល់វាសួរអស់ទៅអាណាធ្វើអី ដល់វាសួរដល់ខ្ញុំ ខ្ញុំអត់បានទេទាហានក៏អត់ធ្វើ ឈ្លបអីក៏គ្មានធ្វើ តែនៅក្នុងភូមិអីគេចាប់ឲ្យយាមអីអាហ្នឹងធ្វើម៉េចបើ នៅក្រោមគេ បើមិនឲ្យខ្ញុំទៅយាមខ្ញុំនៅក្រោមគេម៉េចបានខ្ញុំនិយាយអញ្ចឹងខ្ញុំប្រាប់តាម ហ្នឹងណា៎ ៗ

រឿនៈ ចុះមានគេចេញ ប្រជាជនយើងខ្លះចេញសារភាពសម្ដែងការស្មោះត្រង់ថាខ្ញុំធ្វើប៉ូលីស ធ្លាប់ធ្វើអី មានដែលទេ?

ផាន់: អានេះខ្លះប្រាប់អញ្ចឹង ចាំមើលខ្ញុំប្រាប់ក្មួយឯងណា៎ ។ ប្រាប់អញ្ចឹងគេកត់ហើយណាតែ គេអត់ទាន់អូសរំពេចហ្នឹងអត់ទេ មួយខែពីរខែគេទុកប្រើយើងសិន ប្រើៗគេថាឥឡូវទៅ បេះដូបនៅកន្លែងនេះ ទៅយកផាលនៅកន្លែងនេះអញ្ចឹងណា៎ ម្នាក់ពីរនាក់ណក ធ្វើស្រែ កំប៉ុកជាមួយខ្ញុំ នៅភូមិនោះឈ្មោះអាគុត និងអន្ទិតអីប្អូនតាឌឿ ឈោះតាវៃ ហ្នឹងមួយ គេខឹងខ្លាំងអាហ្នឹងទៅ បាញ់គេយកប្រជាជនគេនៅក្រោមណក គេអត់ទាន់ធ្វើអីដែរអាហ្នឹង តែអត់បានយូរទេ ។

រឿនៈ គាត់ទាហានលន់ នល់ អ្ហែសកាលមុន?

ផាន់: បាទ! ទាហាន លន់ នល់ ។

រឿនៈ គាត់ទៅកៀប្រជាជនមកអ្ហែស?

ផាន់: គាត់មកនៅភូមិខ្ញុំនេះពួកអីទេកាន់ក្ដាប់នៅហ្នឹង គេហៅកុំម៉ង់ដូការពារភូមិណាដើម្បីយកដី ធ្វើស្រែណា៎ បាញ់គ្នាមិនធម្មតាទេ ។ ដល់អញ្ចឹងដល់កំពុងតែធ្វើស្រែ សែបប៉ុស្តិ៍ហ្នឹងខ្លាំង គាត់សែបប៉ុស្តិ៍ក្ដាប់កុំម៉ង់ដូរហ្នឹងណា ដល់អញ្ចឹងចូលមកកណ្ដាប់ដៃគេ គេគ្រាន់តែឃើញ ហ្នឹងគេចង់ស៊ីសាច់បាត់ទៅហើយ តែគេមិនធ្វើណា បានប្រហែលជាពីរអាទិត្យជាមួយ តាវៃ ហ្នឹងគេថាឥឡូងយើងអត់មានផាលភ្ជួរទេយើងទៅយកកន្លែងស្វផាល ៗនៅជិត ព្រៃណក ជិតព្រៃនាម ដល់នេះគេបាញ់ចោលទៅ បិទអត់ឲ្យគេដឹងទេ ។

រឿនៈ តាដឹងដែរអត់កាលហ្នឹង តាដឹងថាគេយកទៅបាញ់ចោលដែរអត់?

ផាន់: តែមិនឃើញទេ គេទៅឯងវាអត់ផាលដាក់ភ្ជួរដល់វាអត់ឃើញណា ទៅយកផាលម៉េចមិន ឃើញមក បាត់បណ្ដោយ ។

រឿនៈ ចុះមានពីណាគេទៀតអត់ដែលត្រូវគេចាប់អញ្ចឹងដែរគេយកទៅបាញ់ចោល?

ផាន់: អាហ្នឹងយូរៗបាត់អញ្ចឹងគេដកអញ្ចឹងណា អានាក់កាន់គេអូរឆ្លើយឆ្លងអីហ្នឹងក៏បាត់ដែរ អាហ្នឹងគេប្រើយូរៗអញ្ចេះទៅ គេនឹកឃើញខឹងគេ គេថាតោះទៅរកបេះដូងកន្ទែងនេះ កាលហ្នុងយើងពុំគេថាបេះដូងអរទៅបាត់បណ្ដោយ ។ នយោបាយគេអញ្ចឹងណា ខ្មែរក្រហមកុំលេងណា មនុស្សយើងស្មើៗ បើហ៊ានសម្ដែងប្រាប់អស់ហ្នឹងដូចខ្ញុំថាអញ្ចឹង ខ្ញុំអត់ទេ ខ្ញុំចាំពាក្យបូរាណថាផ្លូវវៀចកំបែបង់ ផ្លូវណាត្រង់កុំដើរហង ផ្លូវវៀចបើយើងបោះបង់ចោលងាប់ណា ហ្នឹងបើមិនប្រើផ្លូវវៀចងាប់ វាអញ្ចឹងខ្ញុំចាំពាក្យបណ្ដាំពុកខ្ញុំ ។

រឿន: ចុះតាកាលហ្នុងគេឲ្យធ្វើអីដែរ?

ផាន់: ខ្ញុំគ្មានធ្វើអីទេ ធ្វើកាន់តែស្រែហ្នឹងស្ទើរងាប់ហើយ ខ្ញុំប្រាប់ក្មួយឯងថាយើងប្រជាជនថ្មីនេះគេមិនឲ្យធ្វើអីទេ ។

រឿន: ចុះតាថាពេលគេជម្លាសប្រជាជនថ្មីមកពីភ្នំពេញមកគេហៅ ១៧ មេសាអញ្ចឹងអ្វាស់ ។

ផាន់: ខ្ញុំហ្នឹង១៧ដែរ ។

រឿន: តា១៧ដែរ គេឲ្យនៅជាមួយគ្នា ឬក៏គេដាក់ដោយឡែកពីគ្នា?

ផាន់: អានេះនៅជាមួយគ្នាតែគេ គេធ្វើត្រួតពីលើយើងគេក្ដាប់យើង ។

រឿន: អ្នកណាត្រួតពីលើយើង?

ផាន់: អាពួកគេមូលដ្ឋានដែលគេដេកព្រៃហ្នឹងណា ។

រឿន: តែអ្នកហ្នឹងធ្លាប់អ្នកស្រុកភូមិជាមួយគ្នាទេ ពីមុនមក?

ផាន់: បាទ! នៅឆ្ងាយពីគ្នាដូចថាបឹងរូងអីហ្នឹងណា គេអ្នកណាទៅមកវិញគេឡើងធំមិនថាប្រុស មិនថាស្រីទេ គេឡើងក្ដាប់ពីលើយើង យើងគេទុកដូចជាសត្វធាតុអញ្ចឹង គេប្រើទៅណា ពីណាទៅហ៊ានប្រកែក ប្រកែកបាត់ខ្លួនឥឡូវហើយ អត់ទេមុនធ្វើអី ឥឡូវគេប្រជុំធំ គេថាបងប្អូនប្រជាជនទាំងអស់ ឥឡូវគោរពតាមអង្គការយើងចាត់តាំងទេ គោរពទះដៃប្រាវអញ្ចឹង ឲ្យទៅណាក៏ទៅ ខ្ញុំកាលហ្នឹងខ្ញុំឈប់សម្លាប់សត្វហើយ ខ្ញុំឈប់អាយុ៤០ ដល់គេចាត់តាំងឲ្យរកត្រីរកនីងគេទៅ ឯងហ៊ានប្រកែកអ្ហែស ។

រឿនៈ ចុះវត្តអី សាលារៀនអីកាលហ្នុង?

ផាន់ៈ វត្តអីខ្ទេចខ្ទីអស់យកធ្វើផ្ទះបាយអស់ ៗ វិហាហ្នឹងវើអាកំពូលលើអស់កន្លែងហ្នឹងដាក់នារីកាត់ដេរ ៗ

រឿនៈ ដាក់ខាងកងនារីអ្វែស?

ផាន់ៈ ហ្នឹងហើយកងចល័តគេ ៗ

រឿនៈ ចុះព្រះអង្គអីយកទៅណាទៅ?

ផាន់ៈ វ៉ៃខ្ទេច យកមកធ្វើជាអាងនេះ វ៉ៃបាល័ង្កអី វ៉ៃព្រះអី វ៉ៃខ្ទេចខ្ទុំទៅធ្វើឥឡូវហ្នឹងខ្ញុំធ្វើចេតី ៗ

រឿនៈ ចុះតាដូចថាអ្នកមូលដ្ឋាន ប្រជាជនថ្មីអីនៅជាមួយគ្នានៅភូមិអីអញ្ចឹង នៅសហករណ៍អីការរស់នៅការហូបចុកអីជាមួយគ្នាដែរ ឬគេចែកអ្នក១៧ហូបដោយឡែក អ្នកមូលដ្ឋានហូបផ្សេង?

ផាន់ៈ អានេះវាអញ្ចេះឧទាហរណ៍ថា ១៧ ហ្នឹងហើយគេមូលដ្ឋានហ្នឹងគេស៊ីជាមួយយើងចុបៗទៅដល់យើងទៅផ្ទះអស់ គេមានអាកន្លែងសម្ងាត់គេ គេស៊ីបាយអាអែងនេះបបរពីរវែក ភាវកក្លួកអញ្ចឹងទៅ គេធ្វើស៊ីជាមួយយើងដល់នេះខ្ញុំទៅឃើញហើយឯងនេះកាន់ឈើ ជ្រាត់សន្តមឲ្យតែបបរដូចរបៀបកន្ទក់អញ្ចឹងណាដល់ខ្ញុំដើរទៅវាត់កូនគេ អើកូនអាយុ ប្រហែលជា បីបួនឆ្នាំព្រឹកឡើងបាយកកមួយដុំប៉ុននេះ អង្គុយស៊ីមាត់ទ្វា អញ្ចឹងបានជាផាប់ច្រើនណាស់ណា៎ ៗ

រឿនៈ មូលដ្ឋានគេមានកន្លែងសម្ងាត់គេ?

ផាន់ៈ គេមានល្បិចគេអញ្ចឹង ល្បិចគ្នាគេ គេមិនមែនស្គមដូចយើងទេ យើងឡើងភ្លឺកំពស់នេះវាឡើងណាក្លួយ ហើយនារីអាយុ ១៦,១៧ ដូចយាយកញ្ញាស់ពីកាលណាអញ្ចឹងវេទនាណាស់ ៗ

រឿនៈ គាដូចថាការហូបអត់ឆ្អែតអត់អីអញ្ចឹងដោយសាកាលហ្នុងយើងធ្វើស្រូវអត់បាន ឬក៏ដោយសាយ៉ាងម៉េចដែរ?

ផាន់ៈ អាហ្នឹងវាធ្វើហ្នឹង វាខ្វះបច្ចេកទេសផង ក្នុយឯងដឹងស្រាប់ហើយ ឯកជនយើងខំណាស់ណា៎ ឧទាហរណ៍ថាយើងធ្វើខ្ទនយើងមួយព្រឹកនារីមានកម្លាំងដកបានពីរប្ដូន ១ស្មើ៨០កណ្ដាប់ណា ដល់ធ្វើអារបៀបហ្នឹងណា៎ មួយដំបរប្ដូនកណ្ដាប់ពីរដំបរអីហ្នឹង វាអញ្ចឹង ណា៎ វាខុសគ្នា ក្នុងមួយនាក់ហ្នឹងយើងដប់នាក់ធ្វើមិនបានយើងធ្វើទេ ។ អាហ្នឹងហើយក្ដូរអញ្ចឹងដែរតាមគ្នាទៅ មូលនគ្គល័ប្ដូនដប់ម្ភៃ អាខ្លះទម្លាក់តាមគន្លងទៅ វាល្មើយថាវាទប់ ដីទៅ គ្មានបានចំណេញទេ ។

រឿនៈ អស់កម្លាំងមកពីហូបអត់ឆ្អែតអ្ហែស?

ផាន់ៈ បាទ! អាខ្លះគ្នាដួលផាប់នៅនគ្គល័ក៏មានដែរ ខ្ញុំគ្រាន់តែមើលរបៀបដី ដីម្ដុំខាងដើងរបៀបអន្តងដី ចំដីលេខមួយណា ធ្វើសល់ស្រែមិនចេះតិចហិចគា ។

រឿនៈ អត់មានកម្លាំងធ្វើ ។

ផាន់ៈ ហើយវាជំរុញអត់មានពេលឈប់ទេ គោស្គមអស់ហើយប្រើអត់មានដឹងប្រាំងដឹងវស្សាធ្វើស្រែមួយៗមាត់ រើសស្មៅចោលអស់ មិនធ្វើបានច្រើន...ដូចខ្ញុំថាអញ្ចឹងវាស់ដឹងហិចគាប៉ុណ្ណេះៗ គ្រាន់តែស្ទូងហ្នឹងក៏មានតឹកមានដឹង អាណាស្ទូងខុសស្ទូងចាប់បីដើមអាណាលើសក៏មិនបាន អញ្ចឹងបានអីរហ័ស ។

រឿនៈ ប្រិតព្រៀងទាំងអស់តែម្ដង?

ផាន់ៈ បាទ! ដូចខ្ញុំជំរាបក្នុយឯងអញ្ចឹង ដែលខ្ញុំដើរតាមគានោះបានខ្ញុំដឹង ។

រឿនៈ អញ្ចឹងស្រូវធ្វើបានដែរទេគាកាលហ្នុង?

ផាន់ៈ បានតែអត់គ្រប់ ។

រឿនៈ តែហូបអត់គ្រប់អ្ហែស?

ផាន់ៈ បាទ! ខ្ញុំគិតថាក្នុងមួយសហករណ៍នេះបានពីរពាន់ហិចគាឧទាហរណ៍ទេណា ដល់បូកមនុស្សវាបីពាន់គ្រួសារ ហូបគ្រប់ដែរអញ្ចឹង? ខ្ញុំសិក្សាទៅ គាហ្នឹងគាត់អត់ចេះអីខ្ញុំដើរ

ជាមួយគាត់ទៅ ធ្វើរបៀបហ្នឹងផាប់ហើយ ណាគេយកផង គេមិនមែនឲ្យយើងទាំងអស់ទេណា ពេលច្រូតបានអីមកហ្នឹងអង្គការគេដកខ្លះទៅ ។

រឿនៈ គេដកយកទៅណាគេមានប្រាប់ដែរទេ?

ផាន់ៈ អាហ្នឹងគេបញ្ជូនទៅ គេមិនមានប្រាប់អី ឲ្យចិនឲ្យអាណាយើងមាដឹងអីប្រជាជន ។

រឿនៈ គាដូចថាពេលហូបអត់ឆ្អែតអីអញ្ចឹងប្រជាជនយើងមានតវ៉ាអីដែរអត់?

ផាន់ៈ អាហ្នឹងវាអញ្ចេះគេហៅប្រជុំហើយណា៎ តែសហករណ៍គេ គេប្រជុំតែគណៈផ្ទះបាយកាលហ្នុងគេធ្វើរោងដាំបាយរួមហ្នឹងណា គេហៅទៅប្រជុំ មើលដូចថាអញ្ចេះដែរខែបុស ខែមាឃដែលស្រូវទុំហ្នឹងណា៎បានបាយស៊ីហើយ បើមិនអញ្ចឹងមានពីណាច្រូតដល់អញ្ចឹង មើលមកដល់យើងខែចែត្រអីហ្នឹងហៅគណៈផ្ទះបាយទៅប្រជុំជ័យឲ្យហើយទៅ ។

រឿនៈ ម៉េចអញ្ចឹង?

ផាន់ៈ បន្ថយរបប ។

រឿនៈ គេឲ្យមន្ថយរបបអ្វើស?

ផាន់ៈ បន្ថយ ។

រឿនៈ ពីណាគេគណៈផ្ទះបាយកាលហ្នុងគា?

ផាន់ៈ សុទ្ធតែពួកមូលដ្ឋាន យើងអត់មានឲ្យធ្វើមួយទេ ។

រឿនៈ ឈ្មោះអីដែរ គាមានស្គាល់ឈ្មោះគេដែរអត់?

ផាន់ៈ ស្គាល់ខ្លះមិនស្គាល់ខ្លះ គេដូរមិនឲ្យធ្វើជាប់ទេពួកអាហ្នឹងគេមិនមានឲ្យអ្នកឯងធ្វើបានមួយឆ្នាំទេធ្វើបានមួយខែពីរខែគេដូរ គេបង្វិលគ្នាគេហ្នឹង គេអត់ឲ្យយើងបក្សពួកទេ ។

រឿនៈ កាលហ្នុងនៅណាគា?

ផាន់ៈ ខ្ញុំនៅម្រះព្រៅ ។

រឿនៈ គាកាលហ្នុងគេដែលហៅប្រជុំទិទានអីដែរអត់?

ផាន់: អារឿងប្រជុំក្មួយ ខ្ញុំមិនទៅទេ ប្រជុំធំបានទៅ អាហ្នឹងប្រជុំធំហើយណាសហករណ៍អីគេ ទៅ បើនិយាយពីកងចល័តអីដែលគ្នានេះ គ្នាយប់ទៅបោកស្រូវ ម៉ោង១១អីហើយហ្នឹង មកដល់ប្រជុំគ្នាទៀតណា ។

រឿន: ១១យប់?

ផាន់: បាទ! ហើយប្រជុំគ្នាកន្លះម៉ោង មួយម៉ោងអីទៀតបានឲ្យគ្នាដេក ក្រោកពីយប់ទៅបោកស្រូវទៀត ថាឯងខ្ញុំមុនផ្ទះបាយមិនសូវបានប្រជុំនឹងគេទេ ។

រឿន: ម៉េចអញ្ចឹង?

ផាន់: ចុះខ្ញុំកងភ្ជួរកងអីនៅឆ្ងាយពីគ្នា ឆ្ងាយៗណាស់ ។

រឿន: ចុះពេលប្រជុំធំអីភាគច្រើនអ្នកខាងណាគេចុះមកប្រជុំតា?

ផាន់: ខាងឃុំគេ ។

រឿន: គណៈឃុំនៅហ្នឹងគណៈឃុំឈ្មោះអីដែរ?

ផាន់: កន្លែងខ្ញុំគណៈឃុំឈ្មោះ តាចន ដែលខ្ញុំថាហ្នឹងណា ។

រឿន: តាចន ហ្នឹងគណៈឃុំអីដែរ?

ផាន់: គណៈឃុំផងសហករណ៍ផង អាហ្នឹងគេហៅឃុំដប់ ។

រឿន: អត់មានឈ្មោះទេគេហៅអញ្ចឹងតែម្ដង?

ផាន់: បាទ! គេដាក់ឃុំលេខ ១០ អញ្ចឹង ។

រឿន: ឥឡូវនៅឃុំអី?

ផាន់: នៅម្រះព្រៅហ្នឹង អន្ត្រង់ផង ។ អន្ត្រង់ម្រះព្រៅហ្នឹងសរុបគ្នាគេហៅឃុំលេខ១០ ។

រឿន: ឥឡូវគេហៅឃុំអីដែរ?

ផាន់: សព្វថ្ងៃឃុំជ្រៃ ។

រឿន: តាចនហ្នឹងគាត់ក្ដាប់ឃុំហ្នឹងរហូត ឬក៏មានការផ្លាស់ប្ដូរដែរ?

ផាន់: តាចហ្នឹងគាត់នៅដល់យើងចូល ទម្លាក់ពួកនិរតីមកក្ដាប់វិញណា គេដកគាត់ទៅខាងបាត់ដំបង ។

រឿនៈ ពេលនិរតីចូលមកពីណាគេឡើងជំនួសគាចន?

ផាន់ៈ ហ្នឹងគេយកពីគេនោះមក ។

រឿនៈ គាស្គាល់ឈ្មោះគេដែរអត់?

ផាន់ៈ ឈ្មោះ រឿន យកពីនិរតីមក អាហ្នឹងគេឡើងធំហើយណា មកមុនដំបូងមានអីឲ្យប្រជាជនស៊ីគួរសមដែរ ដល់យូរៗទៅអត់ឲ្យប្តីរត់ទៅក្រោមអីមីប្រពន្ធនេះវៃចោលអាកូនតូច គាចវៃចោលអស់ហើយ ។ អត់បានទេនិរតី ។

រឿនៈ ចុះរឿន ឡើងគណៈឃុំដប់ ពីណាគេលើរឿន ហ្នឹងទៀតគាដឹងដែរអត់?

ផាន់ៈ អត់ទេ អគ្គភាពគាត់ខាងយោធា ឈ្មោះ វ៉ន ។

រឿនៈ ខាងយោធាឈ្មោះ វ៉ន ចុះខាងសេដ្ឋកិច្ច?

ផាន់ៈ អាហ្នឹងខ្ញុំអត់ស្គាល់ទេ ។

រឿនៈ មានពីណាគេលើរឿន លើវ៉ន ដែរទេគា?

ផាន់ៈ អាហ្នឹងខ្ញុំអត់ដឹងទេ ។

រឿនៈ វ៉ន មកពីណាដែរគា?

ផាន់ៈ អាហ្នឹងគេហៅពួកនិរតី ពួកវាហ្នឹងក្តាប់យើងពួកយោធាយើងគេដកកាំភ្លើងយកអស់ហើយពួកយើងខាងពាយព្យ័ហ្នឹងគេដកយកអស់ហើយ ។

រឿនៈ

មុនពេលនិរតីមកអ្នកស៍គាដែលព្ទឈ្មោះមេដឹកនាំធំៗដូកគណៈស្រុកអីអ្នកស៍មានស្គាល់ដែរ ទេដូចគាទៅប្រជុំធំៗហ្នឹងណា?

ផាន់ៈ គណៈស្រុកមុនដំបូងឈ្មោះ រ៉េន ។

រឿនៈ គណៈស្រុកមោងហ្នឹងអ្អែស?

ផាន់ៈ បាទ! តែគេដូរពីហ្នឹងទៅមិនដឹងឈ្មោះអីទេ ។

រឿនៈ មានឈ្មោះណោទេ?

ផាន់:	មុនដំបូងឈ្មោះ វេន អាហ្នឹងគណៈស្រុក ។

រឿន:	គណៈស្រុកមោងហ្នឹង?

ផាន់:	បាទ! គណៈស្រុកមោងហ្នឹង វាមួយចំហៀងម្នាក់ណា៎ តំបូនមួយចំហៀង តំបន់ពីរខាងលើនោះមួយចំហៀងគេ...

រឿន:	គេចែកមោងជាពីរទៀតកាលហ្នុង?

ផាន់:	បាទ! គេចែកអាខាងក្រោមថ្នល់អាហ្នឹងតំបន់បួន ពីលើថ្នល់អាហ្នឹងតំបន់ពីរ ។

រឿន:	ខាងក្រោមថ្នល់ហ្នឹងនៅឃុំអីខ្លះ?

ផាន់:	វាដាក់តំបន់បួនហ្នឹងគណៈស្រុកឈ្មោះ វ៉េន ហ្នឹង ។

រឿន:	ចុះខាងណាថ្នល់តំបន់ពីរ?

ផាន់:	តំបន់ពីរលើថ្នល់ជាតិនេះទៅលើ ។

រឿន:	ទៅខាងណាតា?

ផាន់:	ទៅខាងនោះថ្នល់ជាតិ ទៅ...ទៅខាងរុន ទៅគាណាក ទៅអីតាម៉ុកដូចក្នុយឯងថាដូចមាន ឈ្មោះនៅហ្នុងមួយនោះ ។

រឿន:	អាហ្នឹងគេហៅតំបន់ពីរវិញ ។ តាស្គាល់គណៈតំបន់ពីរហ្នឹងពីណាគេដែរអត់?

ផាន់:	អត់ទេអត់ស្គាល់ទេ ។

រឿន:	ចុះតំបន់បួន?

ផាន់:	តំបនបួនគណៈធំគេហ្នឹងនៅ បាត់ដំបងខ្ញុំអត់ស្គាល់ដែរ?

រឿន:	អត់ស្គាល់ដែរ ។ តាដែលឮឈ្មោះតាស៊ុយ តាស៊ូអីដែរទេ?

ផាន់:	តាស៊ុយ តាស៊ូ ហ្នឹងគ្រាន់តែឮមិនដែលឃើញ ។

រឿន:	ចុះគណៈភូមិភាគតានៅពាយព្យ័ហ្នឹងពីណាគេតា?

ផាន់:	អត់ស្គាល់ទេ ស្គាល់ត្រឹមស្រុកទេ អារឿងវ៉ាងអស់ហ្នឹងគេមិនឲ្យយើងដឹងដូចសព្វថ្ងៃនេះទេ ប្រជាជនសូម្បីតែអាពួកចិនពួកអី ដែលវាមកតាមថ្នល់ជាតិហ្នឹងអាណាស្អុមៗវាអត់ឲ្យទៅថ្នល់ជាតិទេ ។

រឿនៈ ម៉េចតាដឹង?

ផាន់: ខ្ញុំបររតេះដឹកអុសដឹកអី ។

រឿនៈ តាថាពីណាគេស្គមអី ម៉េចគេអត់ឲ្យមកថ្នល់ជាតិម៉េច?

ផាន់: អាហ្នឹងគេខ្លាចពួក ដែលគេបើឡានមកមើល ខ្ញុំមិនដឹងខាងណាទេ ដល់គេដឹងថាអញ្ចឹងគេបិទហើយ ។

រឿនៈ ពេលមានគេចុះខាងអ្នកធំៗគេចុះ មានទស្សនៈកិច្ចមកមើលអញ្ចឹងគេអ្នកប្រជាជនណាស្គមឈឺអញ្ចឹង...

ផាន់: អាប្រជាជនស្គមអីគេអត់ឲ្យទៅជិតថ្នល់ទេ ។

រឿនៈ ខាងណាគេអ្នកមកប្រាប់អញ្ចឹង?

ផាន់: ចុះគណៈសហករណ៍ ប្រធានផ្ទះបាយអីគេដំណឹងគ្នាគេមូលដ្ឋាននោះ ដូចថាថ្ងៃហ្នឹងខ្ញុំអ្នកបរទេសហ្នឹងអត់ឲ្យទៅទេ ឲ្យមកកាត់នេះមក ។

រឿនៈ ម៉េចគេខ្លាចអត់ហ៊ានឲ្យអ្នកស្គមអីទៅជិតថ្នល់អញ្ចឹង?

ផាន់: អាហ្នឹងគេរាយការណ៍ទៅលើថាប្រជាជនអត់អីផង ស៊ីបបូរ ដល់ឃើញអាសង្គមអញ្ចឹងគេ ម៉េចជឿ ។

រឿនៈ តាធ្លាប់ឃើញគេចុះមកមើលអីអញ្ចឹងទេ?

ផាន់: អត់ទេ បើគេមិនឲ្យទៅផងបានអីឃើញ ។

រឿនៈ គ្រាន់តែឮថាគេចុះមកអញ្ចឹងគេអត់ឲ្យបរតាមហ្នឹងទេ?

ផាន់: បាទ! គេផ្សាយប្រាប់ផ្ទះបាយយើងនេះ ថាឥឡូវថ្ងៃនេះគេអត់ឲ្យទៅតាមនេះទេ ។

រឿនៈ តាដូចថាតាបររតេះអីអញ្ចឹង កាប់អុសអីហ្នឹងដែលឃើញគេសម្លាប់មនុស្ស គេចាប់មនុស្សអីដែរអត់កាលហ្នុង?

ផាន់: ចំពោះដែលស្លាប់មុនឃើញវ៉ៃកុសដោះអីទេ
តែឃើញសាកសពអីឃើញនៅព្រៃហ្នឹងគេ វ៉ៃចោល ។

រឿនៈ ឃើញសាកសពហ្នឹងយ៉ាងម៉េចតា សភាពត្រូវគេវ៉ៃ ឬអត់អាហារ?

ផាន់៖ អាហ្នឹងយើងមិនបានទៅពិនិត្យអីទេក្មួយអើយ គេលប់អីគ្រាន់តែរុយអីវារោមអីអញ្ចឹង វាកប់វាកាយស្អឹងស្អែងហើយណា ។ បើថាទៅឃើញភ្លាមៗអាហ្នឹងអាចមើលដឹងណ៎ា ។

រឿន៖ គាឃើញច្រើនទេដែលស្លាប់ក្នុងព្រៃហ្នឹង?

ផាន់៖ បើទៅលើច្រើន ។

រឿន៖ ទៅខាងណាគាច្រើនហ្នឹង?

ផាន់៖ នែ៎ ដែលយៀកណាមរំដោះមកជិតហ្នឹងកន្លែងអស់នេះគេរុញទៅលើអស់ទៅភ្នំណ៎ា ទៅហ្នឹងគ្រាន់តែរុយក្មួយអើយចូលមិនចុះទេធំស្អុយប្រហែលវត្តនោះធំស្អុយ កន្លែងដែល សម្លាប់ហ្នឹងណា ។

រឿន៖ ចូលដំបន់ពីរហើយអ្អែស?

ផាន់៖ បាទ! តំបន់ពីរ ។ ដល់ពេលវៀតណាមមកអាតំបន់ក្រោមនេះរត់ទៅហ្នុងបាត់ ។

រឿន៖ គាដូចថាពេលបររតេះអីអញ្ចឹងនៅតាមសហករណ៍អីហ្នឹង មានដែលឃើញគេចងមនុស្ស គេចាប់អីដែរទេ?

ផាន់៖ អត់ទេ ។

រឿន៖ ចុះដែលបាត់មនុស្សទេកាលហ្នុង?

ផាន់៖ អាហ្នឹងគេធ្វើការតែយប់ទេ ។ បើធ្វើថ្ងៃទៅប្រជាជនដឹងច្រើន បើថាចង់យកអ្នកណាយប់ ឡើងគេមកហៅទៅបាត់ ។

រឿន៖ គាដូចថាសម័យហ្នុងគេដាក់ផែនការឲ្យយើងធ្វើប៉ុន្មានៗអញ្ចឹងកំណត់ឲ្យយើងធ្វើ ឬស្រេច តែយើងធ្វើបានប៉ុន្មានយកប៉ុណ្ណឹង?

ផាន់៖ អានេះមានកន្លែងខ្លះកំណត់ដែរ ដូចយើងប្រូតអីគេវាស់ម៉ែតអី វាស់ម៉ែតឲ្យយើងប្រូត ណ៎ា កាលណាយើងប្រូតរួមគ្នាយើងធ្វើដូចថារឡេះរឡោះអីអញ្ចឹង គេវាស់ម៉ែតឲ្យទៅ ។ ខ្ញុំនិយាយត្រង់ទៅលើកភ្លឺអីមិនដែលបោនធ្វើទេ មើលតែក្របីអញ្ចឹង ធ្វើកូនផ្ទះកូនអី ឲ្យគេនៅ ...

ហើយមុខលើកដីលើកអាងអីនេះខ្ញុំអត់ទេ ខ្ញុំមើលក្របីអី ភ្ជួរកងភ្ជួរខ្ញុំមិនទៅពិបាកលើកដីលើកអីទេ ។

រឿនៈ កាលហ្នុងមានដែលពុរឿងខុសខាងសីលធម៌អីដែរអត់តា?

ផាន់ៈ មានមិនអត់ទេ ។

រឿនៈ មានដែរ ។

ផាន់ៈ ខុសសីលធម៌សម្លាប់ចោលបណ្តោយអត់បាច់មានទុកដាក់ទេ ។

រឿនៈ គេចាត់ទុកជាទោសធ្ងន់អ្ហែស?

ផាន់ៈ ទោសធ្ងន់ ។ ខុសសីលធម៌ទាំងពីហ្នឹង ណាកខាងមន្ទីរគេឃុំឃាំងគេនៅវត្តបុប្ផាយើងនៅជិតមោងនេះ **វត្តធម្មយុត្តិ** គេយកទៅដាក់ហ្នឹងវៃចោលហ្នឹងមិនចេះតិចទេហ្នឹង ។

រឿនៈ អាហ្នឹងមន្ទីឃុំឃាំងធំរបស់គេហើយអ្ហែស?

ផាន់ៈ បាទ! អាហ្នឹងមន្ទីរឃុំឃាំងស្រុក ។

រឿនៈ របស់ស្រុកមោង?

ផាន់ៈ បាទ! របស់ស្រុកមោងអាហ្នឹង ។

រឿនៈ អញ្ចឹងតានៅតាមសហករណ៍បើតាមតាធ្លាប់ឆ្លងកាត់មកសម័យហ្នុងអ្ហាស់ ដែលមានអ្នកណាគេខុសសីលធម៌ហើយគេចាប់ទៅដាក់នៅមន្ទីរឃុំឃាំងហ្នឹងដែរអត់?

ផាន់ៈ មាន ។

រឿនៈ មានដែរ?

ផាន់ៈ អាហ្នឹងមកពីភ្នំពេញ ។

រឿនៈ ប្រជាជនថ្មី?

ផាន់ៈ បាទ! មកនៅក្នុម្រះព្រៅហ្នឹង ។

រឿនៈ ខុសយ៉ាងម៉េចតាសីលធម៌ហ្នឹង?

ផាន់ៈ អាគាត់ហ្នឹងអត់មានប្រពន្ធទេ ទៅយកប្រពន្ធគេ ។

រឿនៈ ឈ្មោះ អីដែរតា?

ផាន់: អាហ្នឹងឈ្មោះ អាវ៉ាន់ មីស្រីឈ្មោះអីទេ ប្រពន្ធ ហ៎ំ នេះ ប្តីគាត់ឈ្មោះ ហ៎ំ ។ នៅផ្ទះជិតខ្ញុំហ្នឹង ខ្ញុំស្គាល់ ឈ្មោះ មីស៊ី ទេ...

រឿន: ខុសយ៉ាងម៉េចតាពីរនាក់ហ្នឹង?

ផាន់: ខិលខូច ខិលខូចគ្នាគេរកចាប់រត់ទៅអ្នកតាទ្វាព្រុំប្រទល់ខេត្តពោធិសាត់ហ្នឹងណា រតទៅហ្នឹងគេឲ្យតាមទៅ ឈ្លបគេអីទៅតាមទៅនាំមក ។

រឿន: ពីណាគេអ្នករត់ទៅ ?

ផាន់: អាវ៉ាន់ ហ្នឹងជាមួយប្រពន្ធ ហ៎ំ ហ្នឹង ។

រឿន: រត់ទាំងពីរនាក់ទៅ ?

ផាន់: បាទ! រត់ទាំងពីរនាក់ ហើយយើងជិនាន់ហ្នឹង មានកន្លែងណាគេច បានបាយណាស៊ីអត់រួចគេទេ ហ៊ានធ្វើហ៊ានឆាប់ហើយ ។

រឿន: ដូចថាដល់ពេលរត់ទៅអញ្ចឹងគេទៅតាមចាប់មកវិញអញ្ចឹងគេធ្វើម៉េចទៅ ?

ផាន់: តាមចាប់បានមកគេបញ្ជូនទៅវត្តធម្មយុទ្ធហ្នឹង ។

រឿន: គេអត់មាននាំមកប្រកាលនៅមុខប្រជាជនសិនទេអ្ហែស?

ផាន់: អត់ទេ ។ តែចូលកន្លែងធម្មយុទ្ធអតមានរួចទេ យកទៅវ៉ៃចោលតែម្តង ។

រឿន: ដល់អញ្ចឹង តាថាមិញខុសសីលធម៌ជាមួយប្រពន្ធរបស់តា ហ៎ំ មិនអញ្ចឹងអ្ហែស?

ផាន់: បាទ!

រឿន: ពេលប្រពន្ធគាត់ខូចសីលធម៌អញ្ចឹងតាហ៎ំយ៉ាងម៉េចដែរ?

ផាន់: តាហ៎ំ គាត់មិនដឹងធ្វើម៉េចអង្គការគេដឹងដែរហើយ ។

រឿន: ចុះតាហ៎ំមានទោសអីដែរអត់?

ផាន់: វាគ្មានកន្លែងប្តឹងអីទៀតទេ គេធ្វើបាត់ទៅ ហើយប្តឹងអីទៀត ។

រឿន: ចុះក្រៅពីហ្នឹងមានទៀតទេ តាសីលធម៌?

ផាន់: អាហ្នឹងខ្ញុំអត់ដឹងទេ ។

រឿន: តាដូចថាដល់ពេល ប្រជុំពេលអីគេមានដែលឲ្យយើងរិះគន់គ្នាទៅវិញទៅមកដែរទេ?

ផាន់៖ មានដែរ ។

រឿន៖ រឺះគន់ដែរ?

ផាន់៖ យើងមនុស្សដល់អញ្ចឹងវាដឹកដែរណា ថាគ្នាជួយអាណិតគ្នាអញ្ចឹងទៅ កុំសូវបើកបង្ហាញ គ្នាខ្លាំងពេកយើងអាណិតគ្នាទៅណា ខ្ញុំពេលប្រជុំគ្នានអីទេ ខ្ញុំបីឆ្នាំប្រាំបីខែ ម្ហូបថ្ងៃហ្នឹង មិនដែលពីណាហៅខ្ញុំទៅកសាងទេ ។ ខ្ញុំដឹងល្បិចរបៀបរបបអស់ហ្នឹងណា ខ្ញុំធ្វើមិនឲ្យខុស ទេ បើទោះជាខ្ញុំដាច់ពេលអីខ្ញុំធ្វើខិលខូចអីរបស់ដែលគេមិនឲ្យស៊ី ខ្ញុំមិនដែលឲ្យមានគ្នាទេ ខ្ញុំអត់ទុកចិត្តទេ ។

រឿន៖ ទៅម្នាក់ឯង?

ផាន់៖ បានម្នាក់ឯងអត់មានបបួលអ្នកណាម្នាក់ទេ ។

រឿន៖ គាធ្លាប់លួចអីដែរកាលហ្នុងអ៊ែ្ហស?

ផាន់៖ លួច បើមិនលួចម៉េចរស់ របស់ខ្លួនឯងហ្នឹង ។

រឿន៖ អ! លួចរបស់ខ្លួនឯង?

ផាន់៖ បាទ! ដូចខ្ញុំថាអញ្ចឹងណា សួរយាយខ្ញុំមើល សូម្បីយប់ហ្នឹងយកមកធ្វើទាំងយប់ហ្នឹងអត់មានភ្លើងអុចទេ ធ្វើងងឹត ឈើអាស្រកីហ្នឹងយកទៅដាន់ពន្លិចអត់ឲ្យមានពីណាឃើញទេ ។ អញ្ចឹងបានថាខ្ញុំអត់មានគ្នាទេ អត់ទុកចិត្តគេទេ ខ្លាចគេយកទៅធ្វើខ្លះខ្លាយគេចាប់អានោះ ឯងដែរ ។

រឿន៖ ចុះដូចថាកាលហ្នុងមានប្រជាជនយើងហូបអត់ឆ្អែតអញ្ចឹង នាំគ្នាលួចអីដែរតាអ៊ែ្ហស?

ផាន់៖ អាសហករណ៍ហ្នឹងវាដឹងដែរតើ ។

រឿន៖ ដឹងថាលួចដែរអ៊ែ្ហស?

ផាន់៖ វាដឹងវាថាអាណាដែលនៅរស់នេះសុទ្ធតែអាពួកចោរ វានិយាយអញ្ចឹងបណ្ដោយ ។ និយាយៗទៅ ស៊ើបទាំងអស់គ្នាទៅ ។

រឿន៖ ពេលណានិយាយអញ្ចឹង?

ផាន់ៈ ពេលយើងរួចឆ្លងពីអាផាប់ចង់អស់ អានៅសល់នោះណា ។

រឿនៈ វៀតណាមចូលឬនៅពេលហ្នឹង?

ផាន់ៈ នៅទេ ។ ដល់ពេលបានបាយអីស៊ីខែបុស្ស មាឃ ស្រូវទុំហ្នឹងពេលគេទៅប្រជុំគេនិយាយថាពួកអានៅរស់សុទ្ធតែអាពួកចោរលួច ។ ស៊ីចទាំងអស់គ្នាហ្នឹង ។

រឿនៈ ដូចថាកាលដែលលួចអីអញ្ចឹងដំបូងៗអ្ហាស់
មានអ្នកដែលលួចទៅអញ្ចឹងហើយគេចាប់បាន ថាអ្នកហ្នឹងលួចអ្ហាស់ មានទេ?

ផាន់ៈ អត់សូវអីទេអាលួចស្រូវបូតអីបន្តិចបន្តួចហ្នឹង អាហ្នឹងយកមកកសាងទេ អត់សម្លាប់ទេ អាហ្នឹងគេថាអាហ្នឹងអាចោក្រពះទេ កុំឲ្យសម្លាប់វា ក្រពះវាឃ្លានវាដឹងដែរតើ ។ កូនខ្ញុំវាវ៉ៃវានៅតូចវាទៅបូតស្រូវ គេចាប់វ៉ៃ ។

រឿនៈ កាលហ្នុងតាមានកូនប៉ុន្មាននាក់ហើយ?

ផាន់ៈ កូនខ្ញុំបួន ទេកូនបីទេ កូនទើបតែកើតក្រោយទេ ។

រឿនៈ ពេលមានកូនអញ្ចឹង កូនតាគេឲ្យទៅនៅសហករណ៍ឬនៅតាយាយដែរ?

ផាន់ៈ អាហ្នឹងគេហៅចូលខាងកុមារ អាហ្នឹងវែកអាចម៍វែកអីធ្វើដីធ្វើអីទៅ ។

រឿនៈ ចូលប៉ុន្មាននាក់ដែរកងកុមារហ្នឹង?

ផាន់ៈ ខ្ញុំវាមានមួយតូចនៅអាម្ចាស់ផ្ទះនេះ ។ អាមួយនៅម្រះព្រៅបានប្រពន្ធនៅហ្នឹង អាហ្នឹងតូច កែគេច ចូលធ្វើអាចម៍អីមិនដែលបានយូរទេ គេចទៅនៅជាមួយគេភ្ជួរអីហ្នឹង មើលក្របី ឲ្យគេ អាអ្នកភ្ជួរវាដឹងវាខ្ជិលមើលគោវា អាពួកវាកាន់ក្តាប់កុមារវាទៅសសួរថាទេអត់ ឃើញមកនេះទេ ។ ឲ្យតាតាៗក្តាប់អាកុមារហ្នឹង ។ អញ្ចឹងវាជូនណាចែករបបទៅអារបបគេអានាក់ដែលភ្ជួរហ្នឹងគេឲ្យស៊ីផ្អែតរបស់គេណា ហើយអាអ្នកភ្ជួរហ្នឹងវាល្បិចវាមានចំបើងអីហ្នឹង ពេលដែលកន្ទែងគេបោកគេបែនអីមកដឹកយកមកឲ្យក្របីគោស៊ី យកទៅដល់វាជជុះអាចំបើងហ្នឹង ជជុះបានមួយកូនកញ្ជើអីហ្នឹងមានអាណាទៅមើល ។

រឿនៈ អញ្ចឹងតាត់រត់មកអញ្ចឹងគេអត់ថាអីទេ?

ផាន់៖ ថាអីបើគេអត់ឃើញ?

រឿន៖ ដូចថាគេឲ្យគាត់ទៅរែកអាចម៍អីអញ្ចឹង ហើយកូនតាលួចរត់មកជាមួយអ្នកធំអីអញ្ចឹងគេដឹងដែរទេ?

ផាន់៖ រឿងហ្នឹងអត់ដឹងទេ

វាទៅលាក់ទៅឲ្យឃ្វាលគោពេលថ្ងៃទៅ ព្រៃបាត់ដល់អ្នកទៅក្តាប់ទៅ រកម៉េចឃើញ ទៅសួរ សួរអានាក់ហ្នឹងថាអត់មានកុមារទេកន្លែងហ្នឹង ។

រឿន៖ ដល់បាត់អញ្ចឹងយើងគេឲ្យធ្វើការនៅហ្នឹងទេ ហើយយើងទៅឃ្វាលគោបាត់អញ្ចឹងទៅត្រឡប់មកវិញគេអត់រករឿងទេអ្ហែស?

ផាន់៖ កុមារច្រើនក្នុយ ក្តាប់មិនឈ្នះទេ មានបញ្ជីមានអីណាអត់ទេ ជំនាន់ហ្នុងរកតែស្អីសរសេរមិនចង់បានផង.....

**ចប់កាសែ្សតទីមួយ**

រឿន៖ តាកាលហ្នុងដល់ពេលប្រជាជនយើងឈឺអីអញ្ចឹងអ្នាស់គេឲ្យយកទៅពេទ្យអីដែរទេ?

ផាន់៖ បាទ! គេយកទៅពេទ្យ ។

រឿន៖ ពេទ្យនៅណាដែរតា?

ផាន់៖ ពេទ្យនៅម្រះព្រៅហ្នឹង ពេទ្យហ្នឹងគ្មានបានទៅប្រលងអីណាទេ ពួកមូលដ្ឋានហ្នឹងសំបកឈើ អីហ្នឹង អាអស់ហ្នឹងហៅតែថ្នាំអាចម៍ទន្សាយ ខ្ញុំថាឯងតិចខ្លាស់គេ តិចងាប់អ្ហែង ។

រឿន៖ ជាទេតា មើលជាទេ?

ផាន់៖ ឈឺល្មមៗទៅពេទ្យត្រូវតែងាប់ ។

រឿន៖ ឈឺល្មមៗទៅពេទ្យងាប់?

ផាន់ៈ បាទ! យាយមុិញជូនក្មួយឯងមកមុិញហ្នឹងណា ដែលសុំទៅផ្ទះវិញហ្នឹងណា៎ ប្ដីគាត់នេះ តែគាត់នៅតំបន់លើទេ ។ ហើយខ្ញុំវិសផាប់នឹងគេដែរ តែគេអត់បញ្ជូនទៅពេទ្យទេ បើបញ្ជូនទៅពេទ្យគ្មានបានដល់នេះទេ ។

រឿនៈ ម៉េចបញ្ជូនទៅពេទ្យស្លាប់វិញតា?

ផាន់ៈ ពេទ្យគេមិនយកចិត្តទុកដាក់អីវា គេលើកឡើងថាមនុស្សឈឺសុីបាយវាមិនបានទេឲ្យរបបបន្ថយរបបទៀត ។ ហើយគ្នាឈឺហ្នឹងមិនទៅឈឺអីប៉ុន្មានឈឺនឹងអាអត់សុីហ្នឹងទេ ។ ហើយបើនៅដូចខ្ញុំនៅផ្ទះអីហ្នឹងបានយាយអីជួយរកផ្សែផ្សំអានេះឲ្យសុីអីទៅកូនចៅខ្ញុំ ខ្ញុំរកដើរជីកឫសឈើឲ្យកូនសុីណា កូនខ្ញុំណាចុះបើមានដាច់ពេលទៀតណា បបរពីរវែកទឹកកក្កុកហើយមានថ្ងៃណាអត់គេប្រាប់ផ្ទះបាយថាបងប្អូនថ្ងៃនេះអត់មានបបរទេយើង ។

រឿនៈ គេប្រាប់អញ្ចឹង?

ផាន់ៈ បាទ! ប្រាប់អញ្ចឹង ។

រឿនៈ អត់បបរអញ្ចឹងយើងបានអីហូបទៅ?

ផាន់ៈ អត់ទៅ ។ ហើយខ្ញុំឈ្លាតដាំចេកអីហ្នឹងវាផ្លែអីហ្នឹង លាក់លាមអីទៅកាប់មួយស្និតយក មកស្ងោរចែកកូនសុី ។ រហូតទៅជីកឫសអាដាផ យកមកចែកមកចិតឲ្យកូនសុី ។ ប៉ុណ្ណឹងណាក្មួយ ។

រឿនៈ យើងទៅកាប់ចេកយើងហូបអញ្ចឹងគេអត់ថាអីទេអញ្ចឹងអ្ហែស?

ផាន់ៈ កុំឲ្យតែគេឃើញ ។

រឿនៈ លាក់គេដែរ ។

ផាន់ៈ យើងកាប់ចេកយើងកៀនផ្ទះហ្នឹង ។ យើងមានមាសមានអីដូរគេ ។

រឿនៈ មានមាសដូរបានដែរ?

ផាន់ៈ បាន តែអ្នកដូរហ្នឹងទាល់តែចេះ បើមិនចេះហ្នឹងយាប់ទៀត ។

រឿនៈ ម៉េចអញ្ចឹង ។

ផាន់: ខេត្តឧទាហរណ៍ថាអ្នកមកពីភ្នំពេញអីគេឆែកយករបស់ហើយមាស អត់ទុកទេ រីឯខ្ញុំនៅភូមិករគ្នាឯងនេះគេអត់ឆែកទេ និយាយតាមត្រង់ណា៎ ហើយដូរហ្នឹងដូរទាល់តែចេះដូរបានៗ មិនចេះដូរហ្នឹងគេចាប់ ។

រឿន: ដូរយ៉ាងម៉េចបានៗ ?

ផាន់: អាហ្នឹងខេត្តឧទាហរណ៍ថាកន្លែងខ្ញុំហ្នឹង បងប្អូនយាយហ្នឹងគេធ្វើមេនៅអន្ត្រង ឥឡូវទាក់ទងគ្នាគេថាខ្សែករគេចង់បានតែច្រវ៉ាក់ឆាបទេ

អាផ្ទាំងអំពៅអីអត់យកទេគេប្រាប់ថាអញ្ចឹងណា

អញ្ចឹងយប់ឡើងអាសាក់កាដូរគេហ្នឹងគេដាក់មួយសាក់កាដូគេមកយប់ជ្រៅបន្តិចទៅណា យកមកអន្លុំហ្នឹងមិនសូវជាបាលប៉ុន្មានទេក្មួយអើយលាយស្រូវលាយអីខ្លះដល់អញ្ចឹង យកមកដូមុនដំបូងបាន ៣០ ឬក៏ ២០ ដាំងទេ ។

រឿន: ៣០ កំប៉ុងអ្ហែស?

ផាន់: ៣០ កំប៉ុងមួយដំឡឹងអ្ហាស៎ ។

រឿន: តាទៅដូរអ្ហែស?

ផាន់: គេយកមកដូរដល់ផ្ទះហ្នឹងយប់ទាំងងងឹតណា៎ខ្លាចឈ្លបទៀតណា ។ យប់ម៉ោងដប់ដប់មួយ ហ្នឹងបានហ៊ានធ្វើណា៎ ឲ្យទៅដូរ....

រឿន: មានគេមករកមើលដែរអ្ហែស?

ផាន់: អើ ឈ្លបមកក្រោមផ្ទះអីហ្នឹង ។

រឿន: គេខ្លាចយើងកប់មាសកប់អីហ្នឹងអ្ហែស?

ផាន់: មិនដឹងយ៉ាងម៉េច ។

រឿន: ចុះតាថាយកមាសទៅដូរអន្លុំជាមួយប្រធានសហករណ៍នៅផ្ទះបាយអីអញ្ចឹង?

ផាន់: ទេ អត់បានទេ ។

រឿន: ដូរជាមួយពីណាគេអញ្ចឹង?

ផាន់: ដូចខ្ញុំថាមានខ្សែរយៈ ។

រឿនៈ ដូរជាមួយខ្មែរក្រហមដែរអ្វែស?

ផាន់ៈ អត់ទេ គេមូលដ្ឋានដែរ ដូចខ្ញុំនិយាយប្រាប់មិញថាបងប្អូនគេធ្វើការដែរណា ធ្វើការខ្មែរក្រហមដែរ គេមានអង្កមានអីហើយយើងប្រជាជន ធ្លាប់ដឹងបងប្អូនគេអនុគ្រោះឲ្យយើងផងណា៎ ។

រឿនៈ ចុះគេបានអង្កមកពីណាមកដូរយើង?

ផាន់ៈ ចុះគេមូលដ្ឋានគ្នាគេដូចខ្ញុំថាយើងស៊ីបបរគេស៊ីបាយនោះណា ។

រឿនៈ គេមានលួចកិបកេងអង្កទុកដែរ ។

ផាន់ៈ គេកិប បបរឲ្យយើងស៊ីហ្នឹងគេទុកអង្កហ្នឹងតើ ម្លោះគេចែកគ្នាគេទៅបានខ្សែករពីយើងទៅ ។ យើងដាច់ពេលគេមានចាំតែដាច់ជាមួយយើងតើ មួយៗថាអត់ទេគេស៊ីតែបាយ ។

រឿនៈ ចុះតាកាលសម័យហ្នុងគេថាឲ្យប្រជាជននៅស្មើគ្នាអ្វី?

ផាន់ៈ អើ! មាត់បេះតែថាទៅ ។

រឿនៈ ម៉េចមានបែងចែកប្រជាជនថ្មី ប្រជាជនចាស់?

ផាន់ៈ នៅបែងចែក តែគេនិយាយអញ្ចឹងគេថាអាណានៅផ្ទះធំឥឡូវរើឡងមកនៅតូចឲ្យស្មើ ភាពគ្នា ។

រឿនៈ ចុះគេមាននៅស្មើភាពជាមួយយើងដែរអត់?

ផាន់ៈ គេនៅផ្ទះគេ ស្រួលជាងយើងបន្តិចដែរ ។

រឿនៈ អញ្ចឹងម៉េចស្មើគ្នាតា ។

ផាន់ៈ ចុះមាត់បេះតែថាទៅ ។

រឿនៈ ពេលយើងឃើញអត់ស្មើគ្នាអញ្ចឹងយើងអត់តវ៉ាទេអ្វែសកាលហ្នុង?

ផាន់ៈ ទៅហ៊ានអ្វី បាត់ខ្លួនឥឡូវហ្នឹង ។ មានអាអ្នកធំហ្នឹងណា អាអ្នកធំនៅជាមួយយើងហ្នឹងយកទៅរាយការណ៍ ៗដូចថាយើងហ្នឹងពីសង្គមចាស់ហ្នឹងយើងអ្នកមានណា៎ ។

រឿនៈ គេរាយការណ៍អញ្ចឹងម៉េចទៅ?

ផាន់៖ យើងប្រើងទៅអត់អីទេ គេដឹងមិនបាច់អាតូចៗ រាយការណ៍ក៏ដឹងដែរអាអ្នកធំដូចថាគណៈ សហករណ៍ ចន អីដូចខ្ញុំនិយាយប្រាប់នោះដឹងហើយអាទៅរាយនោះក៏ដឹងដែរ ។

រឿន៖ ចុះតាដូចថាបើយើងប្រៀបធៀបទៅមុនពេលនិរតីមក កាលដែលតាចននៅកាន់កាប់និងពេលនិរតីមក ការរស់នៅរបស់ប្រជាជនដូចគ្នាឬខុសគ្នា?

ផាន់៖ ប្រជាជនដូចខ្ញុំជំរាបប្រាប់ក្មួយឯងអញ្ចឹងថាឥឡូវក្នុងមួយកន្លែងហ្នឹងមានមូលដ្ឋានផ្ទះគេបី បួនក្តាប់ប្រជាជន១៧ធ្វើការងារទាំងអស់ ។

រឿន៖

តែអាការរស់នៅហ្នឹងបើយើងប្រៀបធៀងទៅជាមួយពួកនិរតីមកប្រជាជនរស់នៅស្រួល ជាងពេលពួកនិរតីមកឬក៏ពិបាកជាង?

ផាន់៖ ចាំមើលអាពេលពួកនិរតីមកអាពួកពាយព្យ័យើងនេះ មូលដ្ឋានក៏ដោយ១៧ក៏ដោយ ពួកនិរតីមកវៃស្មើ អាមូលដ្ឋានពាយព្យ័និងអា១៧ ។

រឿន៖ ឲ្យនៅស្មើគ្នាទាំងអស់?

ផាន់៖ ឲ្យនៅស្មើ ហើយគេនៅលើយើងទៅអានិរតីនៅលើយើងទៅ តែប៉ុណ្ណឹង ។

រឿន៖ តែយើងរស់នៅស្រួលជាងមុនឬក៏ពិបាកជាងមុន?

ផាន់៖ អាររឿងហ្នងវាគ្រាន់បន្តិចដែរ និយាយតាមត្រង់ណា ។

រឿន៖ គ្រាន់យ៉ាំងម៉េចតា?

ផាន់៖ គ្រាន់ក្នុងការហូបចុកអី ។

រឿន៖ វាអត់មានការកិបកេងដូចមុនទៀតទេអ្ហែស?

ផាន់៖ ទេកិបមិនកិបមិនដឹងទេអាហ្នឹងគេល្បិចគេ ។

រឿន៖ ឮថាពេលនិរតីមកដំបូងភ្លាមគេឲ្យហូបបាយអ្ហែស?

ផាន់៖ បាទ! បាយហ្នឹង បើបបរហ្នឹងក៏បបរគ្រាន់អត់មានទឹកកក្កូកទេណា៎ នីយាយយុត្តិធម៌ទៅ ។

រឿនៈ ចុះការងារវិញ?

ផាន់ៈ ការងារហ្នឹងមិនខុសមិនត្រូវប៉ុន្មានទេ តែអាមូលដ្ឋានយើងនេះក៏ចុះប្រយុទ្ធដូចគ្នា ភ័យដាងយើងទៀត។ ជួនកាលគេមកគេសួរអ្នកស់ និរតីមកគេខ្សឹបសួរប្រជាជនថ្មី អាណាបន្តត់បាយប្រជាជន សម្លាប់ប្រជាជនច្រើនអីគេសួរអញ្ចឹងអ្នកស់ តែខ្ញុំ....

រឿនៈ ពេលគេសួរអញ្ចឹងមានអ្នក១៧ប្រាប់ទេ?

ផាន់ៈ មានបាត់ខ្លួនខ្លះដែរ។

រឿនៈ ដូចតាចនអីបាត់អត់កាលហ្នុង?

ផាន់ៈ តាចនគាត់ទៅ បាត់ដឹបផុត មានគេយកទៅវ៉ៃដូចខ្ញុំប្រាប់ថា ព្រឹង អីហ្នឹងគេយកទៅវ៉ៃចោល។

រឿនៈ ព្រឹង ហ្នឹងគាត់ធ្វើអីដែរ?

ផាន់ៈ គាត់ធ្វើក្តាប់ខាងយុវជននារី ធ្វើបាបគេពេកអាហ្នឹងតាមបាបកម្មហ្នឹងគេដាក់ច្រវ៉ាក់ទៅសម្លាប់នៅណាកស្រែអូរណាក។

រឿនៈ តាព្រឹង មីងម៉ុន អីហ្នឹងគាត់អ្នកមូលដ្ឋានចាស់?

ផាន់ៈ មូលដ្ឋានចាស់គេឲ្យក្តាប់យុវជននារី។

រឿនៈ ដល់ពេលពួកនិរតីមកគេចាប់តាព្រឹងហ្នឹង?

ផាន់ៈ ចាប់ដាក់ច្រវ៉ាក់។

រឿនៈ តាឃើញគេដាក់ច្រវ៉ាក់បណ្តើរដែរអ្វើស?

ផាន់ៈ អាហ្នឹងវាទៅវ៉ៃគេធ្វើបាបគេណាស់ អាហ្នឹងបាបកម្មវាហុចមកភ្លាម។

រឿនៈ តាដូចថាសម័យខ្មែរក្រហម តាបានឆ្លងកាត់សម័យហ្នឹងអញ្ចឹងតាដឹងថាពីណាគេប្រមុខរដ្ឋជានាយករដ្ឋមន្ត្រីកាន់ក្តាប់ធំជាងគេ តាស្គាល់ដែរទេ?

ផាន់ៈ អត់ស្គាល់ទេក្មួយអើយ
អាហ្នឹងគេនៅថ្នាក់ខេត្តទេណាគេហៅពួកខាងគណៈតំបន់គេនិយាយ
អញ្ចឹងឮតែគេថាមិនដឹងពីណាៗ។

រឿនៈ ធម្មតាប្រទេសមួយវាមិនមានអ្នកដឹកនាំ ។

ផាន់ៈ បើនិយាយទៅ ដូចក្មួយឯងក៏ដឹងដែរ ប៉ុល ពត អីហ្នឹង ។

រឿនៈ តាឮឈ្មោះ ប៉ុល ពត អីដែរអត់កាលហ្នុង?

ផាន់ៈ ឮ មុនដំបូង ខៀវ សំផន ។

រឿនៈ ខៀវ សំផន ហ្នឹងឮតាំងពីឆ្នាំណាមក?

ផាន់ៈ ខៀវ សំផន ហ្នឹងគាត់រត់ចូលព្រៃមុន ។

រឿនៈ តាំងពីសម័យសម្តេចអ៊ួស?

ផាន់ៈ ហ្នឹងហើយ ។ ដល់បាត់ខៀវ សំផន ចេញប៉ុលពត ។

រឿនៈ ចុះតា នួន ជា អីតាដែលឮដែរអត់?

ផាន់ៈ ខ្ញុំមិនសូវដឹងទេ ឮតែ ប៉ុល ពត ហ្នឹងវាទូទៅហើយ អាណាក៏ស្គាល់ដែរ ប៉ុល ពត រហូតមកដល់សព្វថ្ងៃ ។

រឿនៈ ចុះតាដូចថាតាបានឆ្លងកាត់របបហ្នឹងអញ្ចឹង
សព្វថ្ងៃតាមានបាននិយាយរឿងរ៉ាវទាំងអស់
ហ្នឹងប្រាប់ចៅ ៗ ក្រោយ ៗ ឲ្យបានដឹងដែរអត់?

ផាន់ៈ ប្រាប់វាខ្លះដែរដូចខ្ញុំប្រាប់ពីរឿងស៊ីកន្ទុកស៊ីអីគេធ្វើរបបអីម៉េច
ដូនកាលវាចង់ដឹងកូនក្មួយ វាកើតក្មួយអ្ហា៎ស់ ខ្ញុំថាឯងទាំងអស់គ្នាហ្នឹងមិនធ្លាប់លំបាកទេ
កូនខ្ញុំអាធំៗវាដឹង ។

រឿនៈ ចុះចៅ ៗ ជឿទេអញ្ចឹង?

ផាន់ៈ អាខ្លះវាជឿដែរតើ ដូចខ្ញុំថាអើឯងបើដល់ថ្នាក់ដូចអញអ្ហា៎ស់ កន្ទុកហ្នឹងមិនមែនកន្ទុកនេះទេ កន្ទុកវាដាក់ចាក់ចោលក្រោមផ្ទះមាន់ទាជ្រូកអីវាដើរជាន់ ច្រកមកឯងស្មានតែយកមកឲ្យជ្រូកស៊ី មកដល់ឲ្យឯងស៊ី ។

រឿនៈ តាទៅដឹកកន្ទុកហ្នឹងមក?

ផាន់ៈ បាទ!

រឿនៈ គេប្រាប់ថាម៉េចទៅដឹកកន្ទក់ហ្នឹង?

ផាន់ៈ ទៅដល់គេប្រើពីនេះទៅ គេឲ្យទៅដឹកអង្កកាលហ្នុងខ្ញុំមានគោ ខ្ញុំកាន់គោមួយនឹមរតេះមួយ មួយសហករណ៍ផ្ទះបាយហ្នឹងគេឲ្យទៅរតេះបួន ទៅដល់ហ្នុងទៅដល់សួរគេហ្នឹងគេថា មករកអី? គណៈឲ្យមកដឹកអង្ក ។ ឥឡូវគ្មានទេនោះកន្ទក់នោះដឹកយកទៅ ។,

រឿនៈ ទៅដឹកពីណាមក?

ផាន់ៈ មោង ។ ខ្ញុំក៏នឹកឃើញថា បែកដឹកយកមកឲ្យជ្រូកស៊ីហើយអាណាស៊ីកើតបើវក់សំបើមណាស់ និយាយត្រង់ណាមិនមែននិយាយបន្ទើសទេណា ហើយដល់អញ្ចឹងក៏បើដឹងថាគេឲ្យ ស៊ីអញ្ចឹងប្រកមួយការុងទុកខ្លួនឯងបាត់ហើយ បើគេថាយកមកឲ្យជ្រូកស៊ីដឹកធ្វើអីយកតែ ប៉ុណ្ណឹងទៅ គេថាឲ្យបួនហ្នឹងក៏មិនបានពេញល្អដែរលោភយកមកធ្វើអីអញ្ចឹង ប្រកក្របួច បាវមក ។

រឿនៈ ចុះដល់ពេលយកមកដល់?

ផាន់ៈ យកមកដល់គេឲ្យយកទៅដាក់ឃ្លាំងឯស្នានថាយកមកឲ្យជ្រូកស៊ីតើ បានតែប៉ុន្មានថ្ងៃបញ្ចោញអាហ្នឹងចែកបណ្តោយ គេថាអស់អង្កហើយមានតែកន្ទក់ទេ យូរទៅអត់អាកន្ទក់ហ្នឹងស៊ីទៅ ទៀតដាច់ពេល ។

រឿនៈ តាដូចថារឿងប្រវត្តិដែលកើតឡើងសម័យហ្នឹងអញ្ចឹងអ្ហាស៎ តាគិតថារឿងទាំងអស់ហ្នឹងគួតែបំភ្លេចវាចោលកុំរំលឹកវាឬក៏គួតែនិយាយឲ្យក្មេងក្រោយបានដឹងបានឮដែរ?

ផាន់ៈ អាហ្នឹងអាប្រវត្តិដែលជួរចត់ហ្នឹងវាមិនសមណាបំភ្លេចចោលទេ ។

រឿនៈ ហេតុអីទៅ?

ផាន់ៈ ដល់យើងបំភ្លេខចោលទៅ ដល់វាទៅមុខទៀតទៅវាមានអាហ្នឹងចូលយើងមិនអាចដឹងបានណាក្មួយ ។ យើងប្រាប់វាទៅវាដឹង បើនរណាមកឃោសនារបៀបហ្នឹងវាដឹងខ្លួនហើយថាតាអញប្រាប់ថាមិនបានទេវើយអាពួកហ្នឹង...

រឿនៈ អញ្ចឹងវាមានន័យថាកាលដែលយើងនិយាយរឿងរ៉ាវដែលកាលហ្នឹងឲ្យក្មេងៗដឹងហ្នឹង ដើម្បីថ្ងៃក្រោយវាកើតអារបៀបហ្នឹងទៀតអ្ហែសតា?

ផាន់ៈ បាទ! ខ្ញុំជំរាបក្មួយឯងអញ្ចឹង ខ្ញុំនឹកឃើញអញ្ចឹង ខ្ញុំប្រាប់ថាបើពុអាណាឃោសនាខ្មែរក្រហមរបៀបហ្នឹងឯងកុំរើយ ។

រឿនៈ ចុះបើគេឲ្យរត់ចូលព្រៃអីទៀតទៅដែរអត់?

ផាន់ៈ ខ្ញុំប្រាប់វាហើយថាកុំរវីរវល់ សូម្បីតែអាសន្លឹកឆ្នោតយើងដែលបោះហ្នឹងណា ខ្ញុំប្រាប់តើ តែខ្ញុំអត់មានទៅបញ្ចេះថាឯងបោះអានេះអានោះអត់ប្រាប់ទេ អាហ្នឹងយើងវាសុទ្ធតែ បក្សពួកទេណា ខ្ញុំថាសន្លឹកឆ្នោតមួយសន្លឹកមានតំលៃណាស់ណា យើងត្រូវពិនិត្យពិចារ ណាឲ្យបានវែងឆ្ងាយ អារបស់ណាគួមិនគួរសមមិនសមអីត្រូវពិចារណាឲ្យរួចសិនកុំចេះតែ គូសអ្ហាស់ គូសឲ្យតែរួចខ្លួននឹងអាលមកផ្ទះណា ខ្ញុំបោះគ្រប់ត្បិតតែចាស់បុណ្ណឹងអាយុ ៧៦ហ្នឹងហើយ ខ្ញុំទៅ ខ្ញុំបោះ ។

រឿនៈ ចុះតាដូចថាសព្វថ្ងៃតាដែលឮរឿងរ៉ាងដែលថាគេបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរអត់?

ផាន់ៈ ឮតែគេនិយាយយូរហើយតែមិនដែលឃើញកាត់ផង ។

រឿនៈ ឮថាម៉េចដែរតាកាលហ្នុង?

ផាន់ៈ ឮពីរឿងកាត់ទោសខ្មែរក្រហមអីហ្នឹង គេថាវាទាល់តែបានជំនួយពីបរទេសអីជួយមកផងអាហ្នឹងបានកាត់បាន ។

រឿនៈ រឿងហ្នឹងវាអញ្ចេះទេ សព្វថ្ងៃហ្នឹងរដ្ឋាភិបាលយើងនិងអង្គការសហប្រជាជាតិហ្នឹងបានព្រមព្រៀងគ្នាថានឹងបង្កើតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងអ្នកដែលទទួលខុសត្រូវខ្ពស់អ្ហាស់តា ហើយឥឡូវគេចាប់ផ្តើមហើយតុលាការហ្នឹងអ្ហាស់ ។ គេបានរើសចៅក្រមព្រះរាជអាជ្ញា ហើយប៉ុន្មានថ្ងៃមុននោះគេបានថតដាក់ទូរទស្សន៍ដែរចៅក្រមអីទៅស្បថទៅអី ទៅធ្វើសច្ចាប្រនិធាន ហើយសវណាការបើកដំបូងនៅឆ្នាំ

២០០៧ ដើមឆ្នាំអ្នាស់ ។ គេបង្កើតវាដើម្បីរកយុត្តិធម៌ឲ្យជនរងគ្រោះអ្នកដែលស្លាប់នៅក្នុងសម័យហ្នឹង ក៏ដូចជាអ្នកដែលបានរស់រានមានជីវិតដែរអ្នាស់តា ហើយគេធ្វើវាសំរាប់ ប្រជាជន អញ្ចឹងគេចង់ដឹងពីប្រជាជននៅតាមភូមិតាមស្រុកទេសយើងទូទៅ ចង់ដឹងថាតើចង់ឲ្យមានតុលាការហ្នឹងដែរ ឬមិនចាំបាច់ទេ ។ ចំពោះតាផ្ទាល់តាចង់ឲ្យគេបង្កើតតុលាការ ហ្នឹងដែរអត់ ។

ផាន់: តាមពូដែលសម្ដេច ហ៊ុន សែន គាត់និយាយ គាត់ថាដែលកាត់ទោសខ្មែរក្រហមមិនមានឲ្យតុលាការបរទេសទាំងអស់ទេ ទាល់តែមានតុលាការក្នុងប្រទេសយើងផង ។

រឿនៈ បាទ! វាចំរុះគ្នារវាងតុលារការខ្មែរនិងតុលាការបរទេស ព្រោះថាគេថាគេចង់ធ្វើវាដើម្បីប្រទេសខ្មែរ និងដើម្បីជាគំរូផងសំរាប់តុលាការស្រុកខ្មែរយើងផង ។ នៅក្នុងហ្នឹងបើទោះ ជាមានខ្មែរភាគច្រើនមែន ខ្មែរមិនអាចសំរេចចិត្តតែម្នាក់ឯងបានទេ លុះត្រាតែមានសំលេងពីបរទេសដែរបានអាចសំរេចក្ដីបាន ។ អញ្ចឹងតាមចិត្តតាផ្ទាល់តាចង់ឲ្យគេកាត់ទោសមេដឹកនាំខ្មែរក្រហមដែរអត់?

ផាន់: អារឿងហ្នឹងវាមិនមែនសំរេចតែខ្ញុំម្នាក់ឯងទេ ។

រឿនៈ តែបើតាមគំនិតរបស់តាអ្នាស់?

ផាន់: អាហ្នឹងខ្មែរក្រហមវាធ្វើឲ្យវិនាសអន្តរាយព្រាត់ប្រាស់ទ្រព្យសម្បត្តិក្របីគោអី ស្រែភ្លឺអីក៏ដោយបងប្អូនម៉ែឪអីក៏ដោយមកពីខ្មែរក្រហមហ្នឹងណា៎ ម្ល៉ោះហើយកំហឹងម្នាក់ៗវាចេះតែមានហើយ មិនអត់ទេ ។ ដូចខ្ញុំជំរាបក្មួយតាមត្រង់ពីដើមខ្ញុំមិនវេទនាលំបាកអីអញ្ចឹងទេ ។

រឿនៈ អញ្ចឹងតាចង់ឲ្យគេកាត់ទោសដែរ?

ផាន់: អាហ្នឹងទៅតាមផែនការរបស់រដ្ឋទៅ ។

រឿនៈ តាមច្បាប់របស់គេអ្នែស?

ផាន់៖ បាទ! តាមច្បាប់ទៅ ។

រឿន៖ ចុះតាដូចថាបើសិនគេកាត់ទោសមេដឹកនាំធំៗ ព្រោះតុលាការនេះគេកាត់ទោសតែមេដឹកនាំធំប៉ុន្មាននាក់នៅខាងលើទេដូចថាប្រមុខរដ្ឋអីអញ្ចឹងអ្នាស់ គេអត់កាត់ដល់មូលដ្ឋានប្រធានសហករណ៍ គណៈតំបន់ គណៈស្រុក ចំពោះតាផ្ទាល់តាចង់ឲ្យគេកាត់តែមេដឹកនាំធំៗឬចង់ឲ្យគេកាត់ទាំងអ្នកដឹកនាំនៅតាមមូលដ្ឋានទៀត?

ផាន់៖

អាហ្នឹងខ្ញុំសព្វថ្ងៃហ្នឹងវារក្សាសីលទៅ ហើយមិនចង់ទៅផ្ដន្ទាអីអ្នកណាអ្នកណីទេចិត្តរបស់ខ្ញុំ អ្នាស់រក្សាសីលទៅហើយ សព្វថ្ងៃហ្នឹងមើលតែព្រះធម៌ព្រះត្រៃបិតកអីទេម្ល៉ោះហើយ វាគ្មានគំនិតអីទៅចង់ផ្ដន្ទា ឲ្យគេវេទនាដោយសារពាក្យសម្ដីយើងទេ អាហ្នឹងជិរាបក្អួយ ឯងត្រង់ទៅចុះ វាមានធម៌មេត្តាច្រើននៅក្នុងខ្លួនមិនថាអ្នកឯងខុសត្រូវអីលែងចង់ផ្ដន្ទា គេឲ្យវេទនាដោយសារពាក្យសម្ដីខ្ញុំអ្នាស់ ។

រឿន៖ តាបានឆ្លងកាត់របបខ្មែរក្រហមអញ្ចឹងតាមានបាត់បងប្អូនអីដែរអត់?

ផាន់៖ មានខ្លះមិនមែនអត់ទេ បងខ្ញុំបង្កើតហ្នឹងក៏ស្លាប់ដែរ ស្លាប់អស់ពីរបីបងខ្ញុំ មកដល់ពេលនេះដែលខ្ញុំសំរេចចិត្តថាសមាទានខប៉ោសុទ្ធសីលរាល់ថ្ងៃហ្នឹងវាអស់ហើយអាគុំនុំហ្នឹងនោះ ។

រឿន៖ អញ្ចឹងតាគិតថាព្រះពុទ្ធសាសនាយើងមាននាទីសំខាន់ដែរក្នុងការជួយឲ្យយើងសំសាយកំហឹងអ្ហែសតា?

ផាន់៖ បាទ! បើយើងមើលទៅវាដឹងសព្វគ្រប់ស្ដាប់លោកអគ្គបណ្ឌិតអីសម្ដែងអញ្ចឹងទៅវាធូរហើយអាអស់ហ្នឹង វាជារឿងកម្មពារបស់គាត់បណ្ដោយទៅ អាហ្នឹងខ្ញុំពិចារណាអញ្ចឹង ។ ខ្ញុំខឹងណាស់ចង់តែឲ្យកាប់សម្លាប់មិនឲ្យសល់មួយ តែឥឡូវអត់ទេឈប់ហើយ ។

រឿន៖ ចុះដំបូងឡើយខឹងដែរទេ?

ផាន់៖ ខឹងខ្លាំងដែរដូចថាគេឲ្យស៊ីកន្ទក់អី ។

រឿន៖ តាខ្ញុំដូចជាអស់អីចង់សួរតាហើយតាមានអីចង់បន្ថែមអ្វីដែលខ្ញុំអត់បានសួរអ្នាស់?

ផាន់ៈ ខ្ញុំចង់តែអានេះវាខុសដែនការគ្នា បើជំរាបទៅវាមិនបានសំរេចអីក៏មិនដឹងទេណា ខ្ញុំសព្វថ្ងៃហ្នឹងចង់តែឲ្យអង្គការយើងជួយប្រជាជនក្រីក្រខ្សត់ណាស់ក្មួយ

ធ្វើម៉េចជួយគ្នាខ្ញុំឃើញ ផ្ទះគ្នាវេទនាលំបាក ហ្នឹងចិត្តសព្វថ្ងៃហ្នឹងចង់ឲ្យជួយតែប៉ុណ្ណឹងទេ

ហើយខ្ញុំសព្វថ្ងៃធនធាន ចិញ្ចឹមតែអាគ្នាសព្វថ្ងៃនេះកូនគេជួយចិញ្ចឹមផង

ម្លោះហើយមិនអាចទៅជួយបងប្អូន ក្រីក្រណាបានទេ ។

រឿនៈ អញ្ចឹងខ្ញុំអរគុណតាច្រើនតា!

**-ចប់-**